រដ្ឋសភា
ព្រះរាជាណាចក្រកម្ពុជា
នីតិកាលទី៧

ព្រឹត្តិបត្រប្រចាំត្រីមាសទី១ ឆ្នាំ២០២៦
ឆ្នាំទី២៦ លេខ២៥៦ ត្រីមាសទី១ ខែមករា កុម្ភៈ មីនា

រដ្ឋសភា បានអនុម័ត សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញា អង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ សេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងការឆបោក តាមប្រព័ន្ធបច្ចេកវិទ្យា និងសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោត ជ្រើសតាំងសមាជិកព្រឹទ្ធសភា

មាតិកាព័ត៌មាន

ទំព័រ

▷ សកម្មភាពការងាររដ្ឋសភា ប្រចាំខែមករា

-សម្តេចរដ្ឋសភាធិបតី ឃួន សុដារី អញ្ជើញទទួលអំណោយ ថវិកា ១០លានរៀល អង្ករនិងសម្ភារមួយចំនួន................. ១

-គណៈកម្មាធិការអចិន្ត្រៃយ៍ ចាប់ផ្តើមពិនិត្យសិក្សាសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រម............................... ៣

-សម្តេចរដ្ឋសភាធិបតី អញ្ជើញទទួលអំណោយជាថវិកា និងសម្ភារពី លោកជំទាវ ឈរ ណារី ត្រាំអ៊ីវតឹក..................... ៤

-អ្នកវិនិយោគចិននៅកម្ពុជា នាំយកអំណោយសប្បុរសធម៌ជូន សម្តេចប្រធានរដ្ឋសភា សម្រាប់ចែកជូន..................... ៦

-សម្តេចរដ្ឋសភាធិបតី ឃួន សុដារី ស្នើអាពីសិសាអូឌីត ជំរុញកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម វិនិយោគ....................... ៨

-សម្តេចប្រធានរដ្ឋសភា៖ ទំនាក់ទំនងកម្ពុជា-ឡាវ ឈរលើស្មារតីសាមគ្គីភាពយូរអង្វែង គោរពគ្នា.......................... ៩

-សម្តេចរដ្ឋសភាធិបតី អញ្ជើញទទួលអំណោយជាថវិកា និងសម្ភារពីលោកជំទាវឧកញ៉ា ទី គីមស្រ៊ាន.......................... ១១

-សម្តេចប្រធានរដ្ឋសភា អំពាវនាវពលរដ្ឋឱ្យប្រែក្លាយការឈឺចាប់ពីការឈ្លានពានរបស់របស់បរទេស.................... ១២

-រដ្ឋសភា ចាប់ផ្តើមពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការ................ ១៤

- កម្ពុជា-ឥណ្ឌូណេស៊ី ពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរដ្ឋសភាប្រទេសទាំងពីរ.................................... ១៦

ចងក្រង និងផលិតដោយ ការិយាល័យផ្សព្វផ្សាយ

នៃនាយកដ្ឋានព័ត៌មាន អគ្គនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ពិធីការ និងព័ត៌មាន

- គណៈកម្មការត្រួតពិនិត្យ៖ ឯកឧត្តម ឡេង ប៉េងឡុង, ឯកឧត្តមបណ្ឌិត កែវ ពិសិដ្ឋ ឯកឧត្តម ព្រហ្ម វិរៈ, ឯកឧត្តម ញ៉េប ណាវិន

- អាសយដ្ឋាន៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញកម្ពុជា

- ទូរស័ព្ទ៖ (៨៥៥)៧៧ ២៤០ ៥៦៧, (៨៥៥)២៣ ២១០ ៦២៧

- E-mail: communicationna@gmail.com

មាតិកាព័ត៌មាន

ទំព័រ

-សាធារណរដ្ឋកូរ៉េ បន្តលើកកម្ពស់ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយកម្ពុជា.. ១៨

-សម្តេចប្រធានរដ្ឋសភា អញ្ជើញចូលរួមពិធីសូត្រមន្តក្រុងពាលីអគារថ្មី«វិមានសាមគ្គីភាព»................................ ២០

-ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការឥស្សរិយយស................................ ២១

-ឯកឧត្តម វង់ សូត ផ្តល់អនុសាសន៍ដល់យុវជនត្រូវបន្តខិតខំសិក្សារៀនសូត្រ និងអភិវឌ្ឍសមត្ថភាព........................ ២២

-តំណាងសម្តេចប្រធានរដ្ឋសភា និងមូលនិធិសប្បុរសធម៌ប៉ៃលិន នាំយកអំណោយជូនវីរៈកងទ័ពជួរមុខ.................... ២៣

-គណៈកម្មការជំនាញរដ្ឋសភា និងតំណាងរាជរដ្ឋាភិបាលប្រជុំពិនិត្យសិក្សា និងប្រមូលផ្តុំចូល............................ ២៥

-ឯកឧត្តម នឹម ច័ន្ទតារា ទទួលជួបពិភាក្សាការងារជាមួយអនុប្រធានបេសកកម្មស្ថានទូតចក្រភព........................... ២៧

-សម្តេចក្រឡាហោម ស ខេង ប្រគល់គ្រឿងឧបភោគបរិភោគជូនបញ្ជាការដ្ឋានយោធភូមិភាគទី៤......................... ២៨

-គណៈប្រតិភូសភាកម្ពុជា ចូលរួមពិធីបើកមហាសន្និបាតលើកទី១៦ នៃសភាតំបន់អាស៊ី (APA-16)........................ ២៩

-ឯកឧត្តម ទី សុគន្ធ ដឹកនាំគណៈប្រតិភូចូលរួមប្រជុំគណៈកម្មាធិការសិក្សាស្តីពីការកែទម្រង់ AIPACODD................. ៣១

-មន្ត្រីអគ្គលេខាធិការរដ្ឋសភារួមសហការវេចខ្ចប់លើកដាក់អង្ករ និងសម្ភារនានា បញ្ជូនទៅ.. ៣២

-ឯកឧត្តមបណ្ឌិត កែវ ពិសិដ្ឋ ដឹកនាំកិច្ចប្រជុំសម្រេចលើគម្រោងបណ្តុះបណ្តាលមន្ត្រី (អ.ទ.ព.ព)............................ ៣៣

-ថ្នាក់ដឹកនាំអគ្គលេខាធិការរដ្ឋសភា ស្នើសាកលវិទ្យាល័យជុងជី ប្រទេសចិន លើកកម្ពស់កិច្ចការ................................ ៣៤

-អគ្គលេខាធិការដ្ឋានរដ្ឋសភា រៀបចំវគ្គបណ្តុះបណ្តាលស្តីពី «ជំនាញតាក់តែងសង្ខេបគោលនយោបាយ»................ ៣៦

មាតិកាព័ត៌មាន

ទំព័រ

-អគ្គលេខាធិការដ្ឋានរដ្ឋសភា រៀបចំប្រឡងជ្រើសរើសមន្ត្រីកិច្ចសន្យា ៣៧

-អគ្គលេខាធិការដ្ឋានរដ្ឋសភា សម្ពោធជាផ្លូវការបើកវគ្គបណ្តុះបណ្តាលឆ្នាំ២០២៦ .... ៣៨

▷ **សកម្មភាពការងាររដ្ឋសភា ប្រចាំខែកុម្ភៈ**

-សម្តេចប្រធានរដ្ឋសភា និងឯកឧត្តមប្រធានព្រឹទ្ធសភាប៉ាគីស្ថាន ប្តេជ្ញាពង្រឹងកិច្ច..................... ៤០

-ប្រធានរដ្ឋសភាកម្ពុជា-វៀតណាម ជំរុញការលុបបំបាត់ព័ត៌មានក្លែងក្លាយ............................ ៤២

- សម្តេចប្រធានរដ្ឋសភា អញ្ជើញចូលរួមពិធីលៀងសាយភោជនផ្លូវរដ្ឋជូន............................ ៤៤

-សម្តេចរដ្ឋសភាធិបតី ឃួន សុដារី៖ មហាសាមគ្គីជាតិខ្មែរក្រោមការដឹកនាំ............................ ៤៥

-ឈរលើមាគ៌ាសន្តិភាព រដ្ឋសភាកម្ពុជានិងបារាំង ពង្រឹងកិច្ចសហប្រតិបត្តិការ........................ ៤៧

-សម្តេចរដ្ឋសភាធិបតី ឃួន សុដារី៖ ឯកអគ្គរាជទូតត្រូវធ្វើការដោយទន់ភ្លន់............................ ៤៩

-សម្តេចរដ្ឋសភាធិបតី អញ្ជើញថ្វាយព្រះរាជដំណើរ ព្រះករុណាជាអម្ចាស់............................ ៥០

-ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប ដឹកនាំកិច្ចប្រជុំផ្សព្វផ្សាយប្រតិទិន............................ ៥១

-ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប អញ្ជើញចុះពិនិត្យវឌ្ឍនភាពការងារ............................ ៥៣

-ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប គូសបញ្ជាក់ពីមោទនភាពនៃសមិទ្ធផល..................... ៥៤

-គណៈកម្មាធិការផែស្សរិយយសរដ្ឋសភាបញ្ចប់ការវាយតម្លៃនិងត្រៀមបំពាក់........................ ៥៥

-រដ្ឋសភាកម្ពុជា-បារាំង បន្តពង្រឹងចំណងមិត្តភាពឆ្ពោះទៅរក “ភាពជាដៃគូយុទ្ធសាស្ត្រ” ៥៦

-សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន៖ ការបង្កើនសិទ្ធិអំណាចស្ត្រីក្នុងតួនាទីដឹកនាំ............... ៥៨

-រដ្ឋសភាកម្ពុជា សហការជាមួយអង្គការសេកលជំរុញកម្មវិធី «សភាត្រាប់» ដើម្បី................... ៥៩

-ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតសភាចារ្យ សុក ស៊ីផាន់ណា ចែករំលែកទស្សនាទាន................. ៦០

-រដ្ឋសភា សហការជាមួយ UNFPA និង UN Women រៀបចំកម្មវិធី «សភាត្រាប់».................. ៦១

-រដ្ឋសភា ចាប់ដៃគូជាមួយអង្គការសុខភាពពិភពលោក (WHO) ត្រៀមធ្វើម្ចាស់ផ្ទះ.................. ៦៣

-រដ្ឋសភាកម្ពុជា ចូលរួមវគ្គបណ្តុះបណ្តាលអន្តរសភាអាស៊ាន (AIPA)...................................... ៦៤

-ឯកឧត្តម សួស យ៉ារ៉ា បញ្ជាក់ជំហរកម្ពុជាក្នុងការបន្តប្រើប្រាស់ “ច្បាប់អន្តរជាតិ” និង............ ៦៦

-លោកជំទាវ និន សាផុន អញ្ជើញជាអធិបតីពិធីក្រុងពាលីបញ្ចុះបឋមសិលា........................... ៦៧

-រដ្ឋសភាកម្ពុជា បើកការដ្ឋានសាងសង់អគារទីស្នាក់ការថ្មីនៅខេត្តកំពង់ឆ្នាំង........................... ៦៨

-ឯកអគ្គរដ្ឋទូតគុយបា ស្នើរដ្ឋសភាកម្ពុជាបន្តរឹតចំណងមិត្តភាព គាំទ្រគ្នា............................... ៦៩

-ក្រុមអ្នកនយោបាយសភាស្ត្រីកម្ពុជា ជួបតំណាងអង្គការ UN Women និង UNFPA................ ៧០

-ក្រុមប្រឹក្សាអ្នកច្បាប់រដ្ឋសភា កំពុងជំរុញការពិនិត្យឡើងវិញនូវក្របខ័ណ្ឌការងារ.................. ៧១

-អគ្គលេខាធិការដ្ឋានរដ្ឋសភា ត្រៀមបង្កើតអង្គភាពស្រាវជ្រាវ និងបណ្តុះបណ្តាលសភា.......... ៧២

មាតិកាព័ត៌មាន

ទំព័រ

-អគ្គលេខាធិការដ្ឋានរដ្ឋសភា បិទវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីព័ត៌មាន.................. ៧៣
-សភាកម្ពុជា ត្រៀមលក្ខណៈធ្វើជាម្ចាស់ផ្ទះរៀបចំព្រឹត្តិការណ៍អន្តរជាតិធំៗជាច្រើន.................. ៧៤
-រដ្ឋសភាកម្ពុជា កំពុងពន្លឿនការងារបច្ចេកទេសយ៉ាងសកម្ម ដើម្បីត្រៀមរៀបចំ...................... ៧៥
-អគ្គលេខាធិការដ្ឋានរដ្ឋសភា រៀបចំវគ្គបណ្តុះបណ្តាលស្តីពី «ប្រាស្រ័យទាក់ទង..................... ៧៧
-មន្ត្រីរដ្ឋសភា ស្វែងយល់ពីប្រវត្តិទំនាក់ទំនងអន្តរជាតិ និងឫសគល់នយោបាយ...................... ៧៨
-ប្រតិភូសិស្សានុសិស្សសាលាអន្តរជាតិ អាយ.ស៊ី.អេស ធ្វើទស្សនកិច្ចសិក្សាស្វែងយល់......... ៧៩
-អគ្គលេខាធិការដ្ឋាន បិទបញ្ចប់វគ្គបណ្តុះបណ្តាលយុទ្ធសាស្ត្រ «ប្រាស្រ័យទាក់ទង................. ៨១

▷ **សកម្មភាពការងាររដ្ឋសភា ប្រចាំខែមីនា**

-សម្តេចរដ្ឋសភាធិបតី ឃួន សុដារី ទទួលជួបប្រតិភូមជ្ឈមណ្ឌលវប្បធម៌ ព្រះពុទ្ធសាសនា....... ៨២
-ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានរដ្ឋសភា គោរពជូនពរ សម្តេចប្រធានរដ្ឋសភា........................ ៨៤
-សម្តេចប្រធានរដ្ឋសភា ប្រារព្ធពិធីបួងសួងសូមឱ្យកម្ពុជា ថ្នាក់ដឹកនាំ និងពលរដ្ឋទាំងអស់....... ៨៦
-សម្តេចប្រធានរដ្ឋសភា អញ្ជើញជួបសំណេះសំណាល ជាមួយពលរដ្ឋភៀសសឹក................. ៨៧
-សម្តេចប្រធានរដ្ឋសភា៖ បូរណភាពទឹកដី និងសុវត្ថិភាពប្រជាពលរដ្ឋគ្រប់រូប........................ ៨៨
-សម្តេចប្រធានរដ្ឋសភា ស្នើរដ្ឋសភាហុងគ្រីបន្តពង្រឹងកិច្ចសហប្រតិបត្តិការរដ្ឋសភា................ ៩០
-សម្តេចប្រធានរដ្ឋសភា៖ ភាពធន់ជាតិ ចាំបាច់ត្រូវមានគ្រឹះសេដ្ឋកិច្ចដ៏រឹងមាំ........................... ៩២
-គណៈអចិន្ត្រៃយ៍រដ្ឋសភា ទទួលយកសេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងការឆបោក................ ៩៤
-រដ្ឋសភា នឹងពិភាក្សា អនុម័តសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងការឆបោកតាម...................... ៩៥
-រដ្ឋសភា អនុម័តសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា.............. ៩៦
-ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប៖ «ទិវា ៨ មីនា ២០២៦» បង្ហាញពីមោទនភាព............. ៩៧
-រដ្ឋសភាកម្ពុជា៖ កម្ពុជា-កូរ៉េ ប្តេជ្ញាពង្រឹង ការទូតសភា និងជំរុញកិច្ចសហប្រតិបត្តិការ........... ៩៩
-កម្ពុជា បោះជំហានកាន់តែរឹងមាំក្នុងការកសាងភាពធន់ជាតិ និងអធិបតេយ្យសេដ្ឋកិច្ច..............១០០
-ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប ជំរុញនិស្សិតជ័យលាភីអាហារូបករណ៍ MEXT...........១០២
-សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន អញ្ជើញជាអធិបតីអបអរសាទរខួបទី១១៥.................១០៣
-សម្តេចក្រឡាហោម ស ខេង ជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋភៀសសឹក...............១០៤
-កម្ពុជា បង្ហាញពីភាពជោគជ័យនៃរបត់ដឹកនាំបន្តវេន និងតួនាទីសមាជិកសភាវ័យក្មេង............១០៥
-នាយកប្រតិបត្តិអង្គការ PCL៖ ការឈ្លានពានរបស់កងទ័ពថៃមកលើកម្ពុជា.........................១០៦
-គណៈកម្មការទី៩ ចុះពិនិត្យវឌ្ឍនភាពការងារក្រសួងប្រៃសណីយ៍ និងជំរុញការកសាង..........១០៧
-គណៈកម្មការទី៩ ចុះពិនិត្យសមិទ្ធផល «មជ្ឈមណ្ឌលបច្ចេកវិទ្យាសហគមន៍»........................១០៩

មាតិកាព័ត៌មាន

ទំព័រ

-គណៈកម្មការទី១ ចាត់ទុកស្ត្រី ជាកម្លាំងចលករយ៉ាងសំខាន់ក្នុងការអភិវឌ្ឍគ្រួសារ និង...........១១០

-ក្រុមមិត្តភាពរដ្ឋសភាកម្ពុជា-សាធារណរដ្ឋកូរ៉េ ប្តេជ្ញាជំរុញទំនាក់ទំនងសេដ្ឋកិច្ច វប្បធម៌..........១១១

-ឯកឧត្តម សួស យ៉ារ៉ា អញ្ជើញចូលរួមពិធីខួប ៧០ឆ្នាំ នៃទំនាក់ទំនងការទូតកម្ពុជា-ហុងគ្រី.......១១៣

-ឯកឧត្តមបណ្ឌិត លី ឆេង ជំរុញការរៀបចំប្រព័ន្ធ សភាអេឡិចត្រូនិក ដើម្បីពង្រឹង..................១១៤

-លោកជំទាវ និន សាផុន៖ សន្តិភាព និងសន្តិសុខ គឺជាបុរេលក្ខខណ្ឌមិនអាចខ្វះបាន................១១៥

-ឯកឧត្តម សួស យ៉ារ៉ា៖ ការងើបឡើងនៃប្រទេសលោកខាងត្បូង និងផលបច្ច័យ.....................១១៦

-ឯកឧត្តម ឈាង វុន៖ ការប្រើប្រាស់ «ប្រាក់រៀល» ជានិមិត្តរូបនៃអធិបតេយ្យជាតិ និង..........១១៧

-ឯកឧត្តម ឈាង វុន និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានរដ្ឋសភា ចូលរួមប្រារព្ធខួប.................១១៨

-អន្តរគណៈកម្មការរដ្ឋសភា ប្រជុំជាមួយតំណាងរាជរដ្ឋាភិបាលលើសេចក្តីព្រាងច្បាប់............១២០

-ឯកឧត្តម សួស យ៉ារ៉ា ជួបពិភាក្សាជាមួយក្រសួងព័ត៌មាន ដើម្បីពិភាក្សាអំពីវឌ្ឍនភាព...........១២១

-អគ្គលេខាធិការដ្ឋានរដ្ឋសភា បើកការដ្ឋានសាងសង់អគារទីស្នាក់ការថ្មី ខេត្តសៀមរាប...........១២៣

-រដ្ឋសភាកម្ពុជា ប្តេជ្ញាចិត្តខ្ពស់ក្នុងការបង្កើនសមត្ថភាពមន្ត្រីជំនាញ ឆ្លើយតបនឹងផែនការ.........១២៤

-អគ្គលេខាធិការដ្ឋានរដ្ឋសភា បើកការដ្ឋានសាងសង់អគារទីស្នាក់ការថ្មី ខេត្តក្រចេះ................១២៥

-រដ្ឋសភាកម្ពុជា ពង្រឹងសមត្ថភាពមន្ត្រីលើជំនាញ "ការទូតសភា ភាសាបារាំង"..................... ១២៦

-អគ្គលេខាធិការរដ្ឋសភាកម្ពុជា-ហុងគ្រី ប្តេជ្ញាពន្លឿនការអនុវត្ត MOU ក្នុងការពង្រឹង...............១២៧

-ឯកឧត្តមបណ្ឌិត កែវ ពិសិដ្ឋ៖ វគ្គបណ្តុះបណ្តាល ស្តីពី«ជំនាញគ្រប់គ្រងឯកសារ និង............១២៨

-ថ្នាក់ដឹកនាំអគ្គលេខាធិការរដ្ឋសភា បើកកិច្ចពិភាក្សាតុមូលពង្រឹងតួនាទីសេវាគាំទ្រ................១៣០

-ឯកឧត្តមបណ្ឌិត កែវ ពិសិដ្ឋ៖ វិស័យសាធារណៈត្រៀមខ្លួនរួចរាល់ក្នុងការប្រើប្រាស់ប្រាក់.......១៣១

-អគ្គលេខាធិការរដ្ឋសភា បិទវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់បញ្ញាសិប្បនិម្មិត (AI).........១៣៣

សម្តេចរដ្ឋសភាធិបតី ឃួន សុដារី អញ្ជើញទទួលអំណោយជាថវិកា ១០លានរៀល អង្ករនិងសម្ភារមួយចំនួនទៀត ពីលោកជំទាវឧកញ៉ា សុខ សុភាព អគ្គនាយិកាក្រុមហ៊ុនឆាមពាន និងស្វាមី

សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នៅព្រឹកថ្ងៃទី២ ខែមករា ឆ្នាំ២០២៦ បានអញ្ជើញទទួលអំណោយសប្បុរសធម៌ជាថវិកា និងសម្ភារមួយចំនួនពី លោកជំទាវឧកញ៉ា **សុខ សុភាព** អគ្គនាយិកាក្រុមហ៊ុនឆាមពាន និងស្វាមី ដើម្បីបន្តចែកជូនដល់វីរៈកងទ័ព និងពលរដ្ឋភៀសសឹកក្នុងស្មារតីសាមគ្គីជាតិ មហាគ្រួសារខ្មែរដ៏រឹងមាំ ឈរពីក្រោយរាជរដ្ឋាភិបាល និងវីរយុទ្ធជនក្នុងបុព្វហេតុការពារជាតិ និង ការពារប្រជាពលរដ្ឋ។

សម្តេចប្រធានរដ្ឋសភា បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសន្តានចិត្តប្រកបដោយសប្បុរសធម៌របស់ លោកជំទាវឧកញ៉ា ក៏ដូចជាសប្បុរសជនទាំងអស់ ដែលបានចូលរួមបរិច្ចាគនូវធនធានផ្ទាល់ខ្លួនជាកម្លាំងសប្បុរសធម៌មហាគ្រួសារខ្មែរ ស្របតាមការអំពាវនាវរបស់រាជរដ្ឋាភិបាល ក៏ដូចជាថ្នាក់ដឹកនាំកំពូលរបស់ជាតិ ក្នុងស្មារតីមហាគ្រួសារខ្មែរ ជួយសង្គមជាតិក្នុងគ្រាដ៏លំបាកនេះ។

អំណោយសប្បុរសដែល លោកជំទាវឧកញ៉ា **សុខសុភាព** ប្រគល់ជូន **សម្តេចប្រធានរដ្ឋសភា**

នាឱកាសនេះមានថវិកា ១០លានរៀល អង្ករ ១តោន ភេសជ្ជៈ ៥០០កេស។

នៅខណៈនោះ **សម្តេចប្រធានរដ្ឋសភា** បានលើកទឹកចិត្តដល់ លោកជំទាវឧកញ៉ា ក៏ដូចជាអ្នកវិនិយោគក្នុងស្រុកទាំងអស់ សូមបន្តខិតខំប្រែក្លាយឱកាសឈឺចាប់ដែលកម្ពុជាកំពុងជួបប្រទះនេះ ជាកាលានុវត្តថ្មីក្នុងការពង្រឹងខឿនសេដ្ឋកិច្ចជាតិ ដោយរិះរកគ្រប់មធ្យោបាយក្នុងការពង្រីកបង្វាក់ផលិតកម្ម ផលិតជាសម្ភារ និងគ្រឿងឧបភោគ បរិភោគនានាឱ្យបានច្រើន ផ្គត់ផ្គង់ក្នុងស្រុក ជំនួសផលិតផលនាំចូល។ ការផលិតបាននូវផលិតផល ដែលជាតម្រូវការរបស់ប្រជាពលរដ្ឋ មិនត្រឹមជួយឱ្យសេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចគ្រួសារ និងសង្គមជាតិរីកចម្រើនប៉ុណ្ណោះ ទេ ថែមទាំងធ្វើឱ្យកម្ពុជាមានឯករាជ្យ និងម្ចាស់ការលើគ្រប់វិស័យ។

សម្តេច សង្កត់ធ្ងន់ថា “សូមយើងទាំងអស់គ្នាប្តូរការឈឺចាប់ របស់យើងនាពេលនេះ ទៅជាភាពរឹងមាំ និងធន់របស់ជាតិយើង"។

មហាសាមគ្គីគ្រួសារខ្មែរ បានរួមគ្នាជាធ្លុងមួយ និងផុសឡើងយ៉ាងរឹងមាំ ខ្លាំងក្លាជាទីបំផុតដោយ

មិនប្រកាន់និន្នាការនយោបាយ បានឈរយ៉ាងស្វាហាប់ពីក្រោយរាជរដ្ឋាភិបាល និងវីរយុទ្ធជនរបស់យើង។ សកម្មភាពមនុស្សធម៌មហាគ្រួសារខ្មែរនាពេលនេះ ជាការឆ្លើយតបចំពោះគុណបំណាច់យ៉ាងធំធេងរបស់វីរយុទ្ធជន ក្នុងកិច្ចការពារបូរណភាពទឹកដីដ៏អង់អាចក្លាហាន នៅតាមសមរភូមិជួរមុខ។

សម្តេចរដ្ឋសភាធិបតី **ឃួន សុដារី** បានគូសបញ្ជាក់ថា សកម្មភាពមនុស្សធម៌ក្នុងមហាគ្រួសារខ្មែរនាពេលនេះ បានឆ្លុះបញ្ចាំងអំពីការចូលរួមរបស់ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក និងលោកស្រី ក្នុងស្មារតីសាមគ្គីភាព ស្នេហាជាតិ ក្នុងនាមខ្មែរជួយខ្មែរនៅគ្រប់កាលៈទេសៈជាមួយរាជរដ្ឋាភិបាល និងក្នុងស្មារតីសមរភូមិក្រោយគាំទ្រ និងនៅជាប់ជានិច្ចជាមួយសមរភូមិមុខ។

ថ្នាក់ដឹកនាំរដ្ឋសភា សមាជិក សមាជិការដ្ឋសភា ព្រមទាំងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា បានចូលរួមយ៉ាង សស្រាក់សស្រាំទាំងថវិកា កម្លាំងកាយចិត្ត បុះសួរសុខទុក្ខ និងចែកអំណោយសប្បុរសធម៌ជូនវីរយុទ្ធ និងពលរដ្ឋភៀសសឹកគ្រប់គោលដៅយ៉ាងមមាញឹកជាទីបំផុត។

ចំពោះអំណោយសប្បុរសធម៌ ដែលរដ្ឋសភាទទួលបាន បានធ្វើការបែងចែកជូនដល់រដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ដូចជា ខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ និងខេត្តកោះកុង សម្រាប់បែងចែកបន្តជូនវីរៈកងទ័ព និងពលរដ្ឋភៀសសឹក សម្រាប់ចែកជូនវីរយុទ្ធជនកំពុងសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យ និងក្រុមគ្រួសារ វីរយុទ្ធជន ដែលបានពលីជីវិតជាដើម។ រដ្ឋសភា នៅបន្តទទួលអំណោយសម្បុរធម៌ហើយនឹងធ្វើការបែងចែកតាមគោលដៅតម្រូវការ ធ្វើយ៉ាងណា ផ្តល់ភាពកក់ក្តៅ និងផ្សារភ្ជាប់ជានិច្ចរវាងយុទ្ធជនជួរមុខ និងពលរដ្ឋជួរក្រោយ។ **សម្តេចប្រធានរដ្ឋសភា**បានថ្លែងអំណរគុណដល់ពលរដ្ឋទាំងអស់ ដែលជឿជាក់លើថ្នាក់ដឹកនាំ សម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី និងថ្នាក់ដឹកនាំកម្ពុជាទាំងអស់៕

គណៈកម្មាធិការអចិន្ត្រៃយ៍ ចាប់ផ្តើមពិនិត្យសិក្សា សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០២៦ បានបើកកិច្ចប្រជុំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សា និងអនុម័តប្រគល់សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រជូនគណៈកម្មការជំនាញរដ្ឋសភាពិនិត្យសិក្សា។ កិច្ចប្រជុំប្រព្រឹត្តទៅនៅវិមានរដ្ឋសភា ដោយបានពិភាក្សា និងអនុម័ត យល់ ព្រមប្រគល់សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីនីតិសមុទ្រជូន គណៈកម្មការកិច្ចការបរទេស សហ ប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន សហការជាមួយគណៈកម្មការមហាផ្ទៃ ការពារជាតិ មុខងារសាធារណៈ និងកិច្ចការព្រំដែន និងគណៈកម្មការនីតិកម្ម និងយុត្តិធម៌ នៃរដ្ឋសភា ដើម្បីពិនិត្យ សិក្សា និងធ្វើរបាយការណ៍ជូន គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាវិញ ៕

សម្តេចរដ្ឋសភាធិបតី ឃួន សុដារី អញ្ជើញទទួលអំណោយជាថវិកា និងសម្ភារ ពី លោកជំទាវ ឈរ ណារី ត្រាំអ៊ីវតឹក លោកជំទាវ ជូ ញ៉ូ ម៉ិនសម និងលោកជំទាវ ទិត្យ ខាំដារ៉ា នុតសារាន

សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០២៦ បានអញ្ជើញទទួលអំណោយសប្បុរសធម៌ជាថវិកា និងសម្ភារមួយចំនួន ពីលោកជំទាវ **ឈរ ណារី ត្រាំអ៊ីវតឹក** លោកជំទាវ **ជូ ញ៉ូ ម៉ិនសម** និងលោកជំទាវ **ទិត្យ ខាំដារ៉ា នុត សារាន** ទីប្រឹក្សា **សម្តេចប្រធានរដ្ឋសភា** សម្រាប់បន្តចែកជូនដល់វីរៈកងទ័ព និងជនភៀសសឹកក្នុងស្មារតីសាមគ្គីជាតិ មហាគ្រួសារខ្មែរដ៏រឹងមាំឈរពីក្រោយរាជរដ្ឋាភិបាល និងវីរយុទ្ធជនក្នុងបុព្វហេតុការពារជាតិ និងប្រជាពលរដ្ឋ។

សម្តេចប្រធានរដ្ឋសភា បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសន្តានចិត្តប្រកបដោយសប្បុរសធម៌របស់លោកជំទាវទាំងបីរូប ក៏ដូចជាសប្បុរសជនទាំងអស់ ដែលបានចូលរួមបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជាកម្លាំងសប្បុរសធម៌មហាគ្រួសារខ្មែរ តាមការអំពាវនាវរបស់រាជរដ្ឋាភិបាល ក៏ដូចជាថ្នាក់ដឹកនាំកំពូលរបស់ជាតិក្នុងស្មារតីមហាគ្រួសារខ្មែរ ជួយសង្គមជាតិក្នុងគ្រាដ៏លំបាកនេះ។

អំណោយសប្បុរសធម៌ដែល **សម្តេចប្រធានរដ្ឋសភា** ទទួលបាននាពេលនេះមានពីលោកជំទាវ **ឈរ ណារី ត្រាំអ៊ីវតឹក** ថវិកា ១០លានរៀល អង្ករ ១តោន និងអាហារក្រៀម ៣០០កញ្ចប់ ពីលោកជំទាវ **ជូ ញ៉ូ ម៉ិនសម** ថវិកា ១០លានរៀល អង្ករ ១តោន និងពីលោកជំទាវ **ទិត្យ ខាំដារ៉ា នុតសារាន** ថវិកា ១០លានរៀល និងអង្ករ ១តោន។

ក្នុងស្មារតីសមរភូមិក្រោយគាំទ្រ និងនៅជាប់ជានិច្ចជាមួយសមរភូមិជួរមុខ ទាំងថ្នាក់ដឹកនាំរដ្ឋសភា សមាជិក សមាជិការដ្ឋសភា ព្រមទាំងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា បានចូលរួមយ៉ាងសស្រាក់សស្រាំ ទាំងថវិកា កម្លាំងកាយចិត្ត ចុះសួរសុខទុក្ខ និងចែកអំណោយសប្បុរសធម៌ជូនវីរយុទ្ធជន និងពលរដ្ឋភៀសសឹកគ្រប់គោលដៅយ៉ាងមមាញឹកជាទីបំផុត។

ចំពោះអំណោយសប្បុរសធម៌ ដែលរដ្ឋសភាទទួលបានតាមរយៈ **សម្តេចប្រធានរដ្ឋសភា** បានធ្វើការបែងចែកជូនដល់រដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ដូចជា ខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់

ខេត្តកោះកុង សម្រាប់ធ្វើការបែងចែកបន្តជូនវីរៈកងទ័ព និងពលរដ្ឋភៀសសឹក។ ក្រៅពីនេះ ថវិកា និងសម្ភារមួយចំនួនទៀតសម្រាប់ចែកជូនវីរយុទ្ធជនដែលកំពុងសម្រាកព្យាបាល នៅតាមមន្ទីរពេទ្យ និងសម្រាប់ជូនក្រុមគ្រួសារវីរយុទ្ធជន ដែលបានពលីជីវិតជាដើម។

រដ្ឋសភានៅតែបន្តទទួលអំណោយសប្បុរសធម៌ហើយធ្វើការបែងចែកអំណោយទាំងនោះតាមគោលដៅតម្រូវការ ធ្វើយ៉ាងណាផ្តល់ភាពកក់ក្តៅ និងផ្សារភ្ជាប់ជានិច្ចរវាងយុទ្ធជនជួរមុខនិងពលរដ្ឋជួរក្រោយ។

សម្តេចប្រធានរដ្ឋសភា បានថ្លែងអំណរគុណដល់ប្រជាពលរដ្ឋទាំងអស់ ដែលជឿជាក់និងទុកចិត្តលើថ្នាក់ដឹកនាំមាន សម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី និងថ្នាក់ដឹកនាំកម្ពុជាទាំងអស់ក្នុងការដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាងដោយសន្តិវិធី ប្រើប្រាស់យន្តការអន្តរជាតិ និងយន្តការទ្វេភាគី ខិតខំការពារបូរណភាពទឹកដីមិនឱ្យបាត់មួយមីលីម៉ែត្រនោះឡើយ៕

អ្នកវិនិយោគចិននៅកម្ពុជា នាំយកអំណោយសប្បុរសធម៌ជូន សម្តេចប្រធានរដ្ឋសភា សម្រាប់ចែកជូនដល់វីរៈកងទ័ព និងជនភៀសសឹក

សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០២៦ បានអនុញ្ញាតជូនគណៈប្រតិភូធុរជនចិនដែលវិនិយោគនៅកម្ពុជា ដឹកនាំដោយលោកស្រី **ខារី លីវ** នាយិកាប្រតិបត្តិមហាវិទ្យាល័យពាណិជ្ជកម្មអន្តរជាតិ នៃសាកលវិទ្យាល័យអាស៊ី-អឺរ៉ុប ចូលជួបសម្តែងការគួរសម ទទួលអនុសាសន៍ និងប្រគល់អំណោយមនុស្សធម៌ជូន **សម្តេចប្រធានរដ្ឋសភា** សម្រាប់បែងចែកជូនវីរយុទ្ធជននៅសមរភូមិមុខ និងពលរដ្ឋភៀសសឹក។

សម្តេចប្រធានរដ្ឋសភាបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសន្តានចិត្តប្រកបដោយសប្បុរសធម៌ របស់គណៈប្រតិភូជាអ្នកវិនិយោគបរទេសនៅកម្ពុជា បានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជាមួយពលរដ្ឋខ្មែរ ក្នុងគ្រាដ៏លំបាកដែលកម្ពុជាបានជួបប្រទះនេះ។ **សម្តេចប្រធាន**បានគូសបញ្ជាក់ថា កាយវិការមនុស្សធម៌នេះ បានឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីចំណងមិត្តភាពដែកថែកម្ពុជា និងចិន ដែលបានចាក់ឫសយ៉ាងជ្រៅនៅគ្រប់ស្រទាប់វណ្ណៈ រវាងប្រជាជន និងប្រជាជន ថ្នាក់ដឹកនាំ និងថ្នាក់ដឹកនាំក៏ដូចជាស្ថាប័ននិងស្ថាប័ន។

កាយវិការមនុស្សធម៌នៅក្នុងឱកាសនេះបង្ហាញពីស្មារតីមនុស្សធម៌ ចំណងមិត្តភាព សាមគ្គីដ៏ស្មោះរវាងប្រជាជននៃប្រទេសទាំងពីរ ដូចពាក្យស្លោកថា "មិត្តល្អជួយគ្នានៅគ្រាមានការលំបាក"។ **សម្តេចរដ្ឋសភាធិបតី** បានជម្រាបពីស្ថានការណ៍សង្គ្រាម

ឈ្លានពានរបស់ប្រទេសថៃមកលើអធិបតេយ្យកម្ពុជា និងបានថ្លែងអំណរគុណដល់រដ្ឋាភិបាលប្រទេសចិន ដែលបានដើរតួនាទីដ៏សំខាន់ នៅក្នុងការសម្របសម្រួលឱ្យមានការអនុវត្តបទឈប់បាញ់ប្រកបដោយប្រសិទ្ធភាព តាមរយៈជំនួបត្រីភាគីរវាងរដ្ឋមន្ត្រីការបរទេសកម្ពុជា និងថៃ ក្រោមការសម្របសម្រួលរបស់ ឯកឧត្តម **វ៉ាង យី** រដ្ឋមន្ត្រីការបរទេសចិន កាលពីថ្ងៃទី២៨ និង២៩ ខែធ្នូ នៅខេត្តយូណាន។

ជាមួយគ្នានេះ **សម្ដេច**ក៏បានថ្លែងអំណរគុណដល់មិត្តចិន ដែលបានផ្ដល់ជំនួយមនុស្សធម៌បន្ទាន់ចំនួន ២០លានយន់ ដល់រដ្ឋាភិបាលកម្ពុជា ដើម្បីជួយជនស៊ីវិលភៀសខ្លួន ដែលកំពុងរងផលប៉ះពាល់ដោយជម្លោះព្រំដែនកម្ពុជា-ថៃ ផងដែរ។

លោកស្រី **ខារី លីវ** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូន **សម្ដេចប្រធានរដ្ឋសភា** ដែលបានឆ្លៀតពេលមកញឹកទទួលជួបគណៈប្រតិភូវិនិយោគចិន នៅកម្ពុជានាឱកាសនេះ។ លោកស្រីបានបញ្ជាក់ថា គណៈប្រតិភូដែលបានចូលជួបសម្ដែងការគួរសមនាពេលនេះជាវិនិយោគិនក្នុងវិស័យផ្សេងៗ ដែលម្នាក់ៗ បានបោះទុនវិយោគនៅកម្ពុជាក្នុងរយៈពេលលើសពី ១០ឆ្នាំមកហើយ។

កម្ពុជាបានផ្ដល់ឱកាសល្អសម្រាប់ការវិនិយោគ និងរស់នៅយ៉ាងសុខដុម ដូច្នេះការចូលរួមចំណែកបរិច្ចាគជួយសង្គមកម្ពុជា ជាការតបស្នងសងគុណដល់ប្រទេស និងប្រជាជនកម្ពុជាវិញ។

លោកស្រីបានសម្ដែងការកោតសរសើរចំពោះសមត្ថភាព និងទេព្យកោសល្យដឹកនាំស្ថាប័នរដ្ឋសភារបស់ **សម្ដេចប្រធាន** ដោយបានបញ្ជាក់ថា **សម្ដេច** ជាស្ត្រីគំរូរបស់ពួកគាត់ទាំងអស់គ្នា។

អំណោយដែលគណៈប្រតិភូវិនិយោគចិននៅកម្ពុជា បានប្រគល់ជូន **សម្ដេចប្រធានរដ្ឋសភា** នាពេលនេះមានអង្ករ ១០តោន ទឹកបរិសុទ្ធ ៥០០កេស នំ ១៥កេស និងមីកំប៉ុង ២៥០កេស។

សម្ដេចប្រធានរដ្ឋសភា បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអ្នកវិនិយោគបរទេស នៅកម្ពុជា ដែលបានជឿជាក់លើការដឹកនាំរបស់រាជរដ្ឋាភិបាល និងបានស្នើដល់អ្នកវិយោគទាំងអស់នៅកម្ពុជាប្រែក្លាយឱកាសដែលកម្ពុជាកំពុងប្រឈមទៅជាកាលានុវត្តន៍ថ្មី ក្នុងការពង្រឹងមុខជំនួញរបស់ខ្លួនឱ្យរីកចម្រើន និងប្រកបដោយសក្ដានុពលកាន់តែខ្លាំងក្លាបន្ថែមទៀត៕

សម្តេចរដ្ឋសភាធិបតី ឃួន សុដារី ស្នើអារ៉ាប៊ីសាអូឌីត ជំរុញកិច្ចសហប្រតិបត្តិការ ពាណិជ្ជកម្ម វិនិយោគនិងទេសចរណ៍ ឱ្យបានកាន់តែច្រើនឡើងបន្ថែមទៀត

សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា នៅថ្ងៃទី៨ ខែមករា ឆ្នាំ២០២៦ បាន អនុញ្ញាតជូន ឯកឧត្តម **មូហាម៉េដ អ៊ីសម្មាអ៊ីល អេ. ដាលវី** (Mohammed Ismaeil A. Dahlwy) ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត ប្រចាំកម្ពុជាចូលជួបសម្តែងការគួរសម និងជម្រាបលា បន្ទាប់ពី ឯកឧត្តមបានបញ្ចប់បេសកកម្មការទូតនៅកម្ពុជា ។

សម្តេចរដ្ឋសភាធិបតី បានសម្តែងនូវការស្វាគមន៍ និងពេញចិត្តជាខ្លាំងចំពោះលទ្ធផលការងារក្នុងអាណត្តិបេសកកម្មការទូតរបស់ ឯកឧត្តម ដែលសម្រេចបាននូវផ្លែផ្កាគួរជាទីមោទនៈ នាំមកនូវផលប្រយោជន៍ដល់ប្រទេស និងប្រជាជន នៃប្រទេសទាំងពីរក៏ដូចជារួមចំណែកដល់តំបន់និងសកលលោកផងដែរ ។ ទំនាក់ទំនងកម្ពុជា និងអារ៉ាប៊ីសាអូឌីត មានការរីកចម្រើនស្ទើរគ្រប់វិស័យ ទាំងស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ ។ ក្នុងនោះថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ បានផ្លាស់ប្តូរដំណើរទស្សនកិច្ចជាបន្តបន្ទាប់ ។ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភាកម្ពុជា បានបំពេញទស្សនកិច្ច នៅព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត កាលពីឆ្នាំ២០២៤ កន្លងទៅ ហើយ ឯកឧត្តមប្រធានរដ្ឋសភាអារ៉ាប៊ីសាអូឌីត ក៏បានអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជា កាលពីខែកក្កដា ឆ្នាំ ២០២៥ ផងដែរ ។

សម្តេចរដ្ឋសភាធិបតី **ឃួន សុដារី** បានបញ្ជាក់ថា តាមរយៈការផ្លាស់ប្តូរដំណើរទស្សនកិច្ចគ្នាទៅវិញទៅមកនាពេលកន្លងទៅ ជាផ្នែកមួយធ្វើឱ្យទំនាក់ទំនងប្រទេសទាំងពីរ កាន់តែមានការរីកចម្រើន និងជិតស្និទ្ធ ។

ឯកឧត្តមឯកអគ្គរាជទូតអារ៉ាប៊ីសាអូឌីត បានអរគុណចំពោះ **សម្តេចរដ្ឋសភាធិបតី** ដែលបានអនុញ្ញាតឱ្យ ឯកឧត្តម ចូលជួបសម្តែងការគួរសម និងជម្រាបលានាពេលនេះ ។ ឯកឧត្តមបានជម្រាបជូន **សម្តេចប្រធានរដ្ឋសភា** ពីលទ្ធផលការងារជាច្រើន ដែលសម្រេចបានក្នុងរយៈពេល ៣ឆ្នាំនេះ ។

សម្តេចប្រធានរដ្ឋសភា បានគូសបញ្ជាក់ថា ទំនាក់ទំនង កិច្ចសហប្រតិបត្តិការកម្ពុជា និងអារ៉ាប៊ីសាអូឌីត មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ឈរលើស្មារតីស្មោះត្រង់ ជឿជាក់ និងយោគយល់គ្នាទៅវិញទៅមក ។

ប្រទេសទាំងពីរមានសក្តានុពល ជាច្រើនទៀតដែលត្រូវសហការគ្នាបន្ថែមទៀតដូចជាវិស័យ ពាណិជ្ជកម្ម វិនិយោគទេសចរណ៍និងអប់រំជាដើម។**សម្តេចប្រធានរដ្ឋសភា**បានសង្កត់ធ្ងន់ថា ទំនាក់ទំនងរវាង ប្រជាជន និងប្រជាជន គឺជាកត្តាសំខាន់ក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ។ អារ៉ាប៊ីសាអូឌីត គឺជាប្រកទំនាក់ទំនងដ៏សំខាន់រវាងអាស៊ី និងមជ្ឈិមបូព៌ា។ អារ៉ាប៊ីសាអូឌីត គួរមើលកម្ពុជាឱ្យហួសពីកម្ពុជា គឺមើលកម្ពុជាក្នុងក្របខ័ណ្ឌអាស៊ាន និងក្នុងក្របខ័ណ្ឌ ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់(RCEP)ជាទីផ្សារសេដ្ឋកិច្ចមួយយ៉ាងធំ។ **សម្តេច**ក៏បានស្នើឱ្យអារ៉ាប៊ីសាអូឌីត ជំរុញឱ្យមានជើងហោះត្រង់រវាងប្រទេសទាំងពីរផងដែរ។

ឯកឧត្តម **មូហាម៉េដ អ៊ីស្មាអ៊ីល អេ.ដាល ទី** គាំទ្រប្រសាសន៍លើកឡើងរបស់ **សម្តេចប្រធាន** និងបានបញ្ជាក់ថា ទោះបីបេសកកម្មការទូតរបស់ឯកឧត្តម ត្រូវបានបញ្ចប់ទៅយ៉ាងណាក្តីក៏ ឯកឧត្តមនឹងខិតខំជំរុញ និងលើកកម្ពស់កិច្ចសហប្រតិបត្តិការប្រទេសទាំងពីរឱ្យមានការរីចម្រើនបន្ថែមទៀត តាមរយៈការផ្លាស់ប្តូរទស្សនកិច្ចទៅវិញទៅមក របស់ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ។

ឯកឧត្តមបានបញ្ជាក់ថា ក្នុងឆ្នាំ២០២៦ នេះ អ្នកវិនិយោគអារ៉ាប៊ីសាអូឌីត នឹងមកបំពេញទស្សនកិច្ចនៅកម្ពុជា ដើម្បីស្វែងរកឱកាសវិនិយោគ៕

សម្តេចប្រធានរដ្ឋសភា៖ ទំនាក់ទំនងកម្ពុជា-ឡាវ ឈរលើស្មារតីសាមគ្គីភាពយូរអង្វែង គោរពគ្នា និងរក្សាផលប្រយោជន៍ទៅវិញទៅមក

សម្តេចមហារដ្ឋសភាធិការធិបតី **ឃួនសុដារី** ប្រធានរដ្ឋសភានៅថ្ងៃទី៨ខែមករាឆ្នាំ២០២៦បាន អនុញ្ញាតជូន ឯកឧត្តម **បួកែវ ភុំវង្សសាយ** (Buakeo PHUMVONGSAY) ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវប្រចាំកម្ពុជា ដែលត្រូវចប់អាណត្តិបេសកកម្មការទូតពីកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា នៅវិមានរដ្ឋសភា។



សម្តេចប្រធានរដ្ឋសភាបានថ្លែងកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលសំខាន់នានា ដែល ឯកឧត្តមឯកអគ្គរដ្ឋទូត និងសហការី ខិតខំប្រឹងប្រែង និងសម្រេចបាននាពេលកន្លងមក ដោយបានរួមចំណែកយ៉ាងសំខាន់ដល់ការពង្រឹង ពង្រីក និងលើកកម្ពស់ទំនាក់ទំនង កិច្ចសហប្រតិបត្តិការ រវាងប្រទេសទាំងពីរ ទាំងក្នុងក្របខ័ណ្ឌនីតិប្រតិបត្តិ នីតិប្បញ្ញត្តិ បក្ស ធុរកិច្ច និងទំនាក់ទំនងរវាងប្រជាជន និងប្រជាជន ដោយបាននាំមកនូវផលប្រយោជន៍ ជូនដល់ប្រទេសនិងប្រជាជនទាំងសងខាង។

សម្តេចរដ្ឋសភាធិបតី បានសង្កត់ធ្ងន់ថា កម្ពុជានិងឡាវ ជាអ្នកជិតខាងល្អ ជាមិត្តដ៏ជិតស្និទ្ធ ប្រៀបដូចបងប្អូន ឬជន្លងនឹងគ្នា ដែលជានិច្ចកាលជួយគ្នាទៅវិញទៅមកក្នុងគ្រប់កាលៈទេសៈ។ មិត្តភាពប្រទេសទាំងពីរ ត្រូវបានបន្តលើកកម្ពស់ដោយថ្នាក់ដឹកនាំគ្រប់ជំនាន់ ឈរលើស្មារតីសាមគ្គីភាពយូរអង្វែង ដោយជឿជាក់គ្នា យោគយល់គ្នា គោរពគ្នាទៅវិញទៅមក និងផ្តល់ផលប្រយោជន៍ឱ្យគ្នាស្របតាមទិសស្លោក "អ្នកជិតខាងល្អ មិត្តភាព ជាប្រពៃណី កិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ និងនិរន្តរភាពយូរអង្វែង"។

សម្តេចប្រធានរដ្ឋសភាបានគូសបញ្ជាក់ថា ក្នុងនាមជាប្រទេសតូច កម្ពុជាមិនខុសពីឡាវនោះទេ បានខិតខំអភិវឌ្ឍប្រទេសជាតិ ពង្រឹងកិច្ចសហប្រតិបត្តិការ លើកកម្ពស់គោលការណ៍ពហុនិយម និងគោរពច្បាប់អន្តរជាតិ ដើម្បីធានាសុខសន្តិភាពសម្រាប់ប្រទេសជាតិខ្លួន ក៏ដូចជានៅក្នុងតំបន់ និងអន្តរជាតិផងដែរ។ សុខសន្តិភាពមានសារៈសំខាន់ណាស់ ព្រោះថា សង្គ្រាមគ្មានផលចំណេញអ្វីឡើយ គឺមានតែចាញ់ ចាញ់ទាំងអស់គ្នា។

ប្រទេសតូចដូចកម្ពុជា គ្មានមហិច្ឆតាណាមួយទៅឈ្លានពានប្រទេសធំឡើយ។

ឯកឧត្តម **ឃួកែវ ភុំចន្ទសាយ** បានឯកភាពចំពោះការលើកឡើងរបស់**សម្តេច** និងបានគូសបញ្ជាក់ពីតម្លៃសន្តិភាព និងជឿជាក់យ៉ាងមុតមាំថា ជម្លោះព្រំដែនកម្ពុជានិងថៃ នឹងអាចដោះស្រាយដោយសន្តិវិធីក្នុងពេលឆាប់ៗនេះ។ ជាមួយគ្នានោះ ឯកឧត្តមឯកអគ្គរដ្ឋទូតក៏បានចែករំលែកអំពីសភាពការណ៍និងព័ត៌មានថ្មីៗ ដែលកំពុងកើតមាននៅក្នុងប្រទេសឡាវជូន **សម្តេចប្រធាន** ដោយបានគូសបញ្ជាក់ថា ខណៈនេះ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ បាននិងកំពុងរៀបចំមហាសន្និបាតលើកទី១២ របស់បក្សប្រជាជនបដិវត្តន៍ឡាវ ដើម្បីវាយតម្លៃការងារ ដែលបានអនុវត្តកន្លងមក និងលើកទិសដៅសម្រាប់ឆ្នាំ ២០២៦-២០៣០។

ឯកឧត្តមបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **សម្តេចប្រធានរដ្ឋសភា** ក៏ដូចជារដ្ឋសភា ដែលបានផ្តល់កិច្ចសហការ និងគាំទ្រយ៉ាជិតស្និទ្ធ ជាមួយស្ថានទូតប្រទេសឡាវប្រចាំកម្ពុជា និងបានបញ្ចប់ទៅប្រកបដោយផ្លែផ្កាគួរជាទីមោទនៈ រួមចំណែកក្នុងការលើកកម្ពស់ទំនាក់ទំនង កិច្ចសហប្រតិបត្តិការប្រទេសទាំងពីរ ដែលមានតាំងពីយូរលង់ណាស់មកហើយ ឱ្យកាន់តែរឹងមាំថែមទៀត៕

សម្តេចរដ្ឋសភាធិបតី ឃួន សុដារី អញ្ជើញទទួលអំណោយជាថវិកា និងសម្ភារពី លោកជំទាវឧកញ៉ា ទី គីមស្រ៊ាន និងស្វាមី អ្នកឧកញ៉ា ឌុក ទីប៉ាណា និងលោកជំទាវឧកញ៉ា ហាក់ តាំងណៃ

សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នៅព្រឹកថ្ងៃទី៨ ខែមករា ឆ្នាំ២០២៦ បានអញ្ជើញទទួលអំណោយសប្បុរសធម៌ ជាថវិកា និងសម្ភារមួយចំនួនពីលោកជំទាវឧកញ៉ា **ទី គីមស្រ៊ាន** សមាជិកក្រុមប្រឹក្សាភិបាល នៃសមាគមឧកញ៉ាកម្ពុជា និងស្វាមី អ្នកឧកញ៉ា **ឌុក ទីប៉ាណា** និងពីលោកជំទាវឧកញ៉ា **ហាក់ តាំងណៃ** សម្រាប់បន្តចែកជូនដល់វីរៈកងទ័ព និងជនភៀសសឹកក្នុងស្មារតីសាមគ្គីជាតិមហាគ្រួសារខ្មែរដ៏រឹងមាំ ឈរពីក្រោយរាជរដ្ឋាភិបាល និងវីរយុទ្ធជន ក្នុងបុព្វហេតុការពារជាតិ និងការពារប្រជាពលរដ្ឋ។

សម្តេចប្រធានរដ្ឋសភា បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅនូវសន្តានចិត្តសប្បុរសរបស់លោកជំទាវឧកញ៉ាទាំងពីររូប ក៏ដូចជាសប្បុរសជនទាំងអស់ ដែលបានចូលរួមបរិច្ចាគនូវធនធានផ្ទាល់ខ្លួន ជាកម្លាំងសប្បុរសធម៌មហាគ្រួសារខ្មែរ តាមរយៈ**សម្តេច**ក្តី និងតាមរយៈថ្នាក់ដឹកនាំស្ថាប័ននានាក្តី សុទ្ធសឹងជាកាយវិការមនុស្សធម៌ គួរជាទីគោរព ស្របតាមការអំពាវនាវរបស់រាជរដ្ឋាភិបាល ក៏ដូចជាថ្នាក់ដឹកនាំកំពូលរបស់ជាតិ ក្នុងស្មារតីមហាគ្រួសារខ្មែរ ជួយសង្គមជាតិក្នុងគ្រាដ៏លំបាកនេះ។

អំណោយសប្បុរសធម៌ដែល **សម្តេចប្រធានរដ្ឋសភា** ទទួលបានពីលោកជំទាវឧកញ៉ា **ទី គីមស្រ៊ាន** និងស្វាមី អ្នកឧកញ៉ា **ឌុក ទីប៉ាណា** នៅក្នុងឱកាសនោះ មានអង្ករ ១តោន ខោអាវ ២០គីប និងថវិកា ២លានរៀល ។ ចំណែកអំណោយរបស់លោកជំទាវឧកញ៉ា **ហាក់ តាំងណៃ** មានផ្អកត្រី ២០០គីឡូក្រាម និងអាល់កុល ២០កេស។

សម្តេចប្រធានរដ្ឋសភាបានមានប្រសាសន៍លើកឡើងថា មហាសាមគ្គីគ្រួសារខ្មែរ បានរួមគ្នាជាធ្លុងមួយផុសឡើងយ៉ាងរឹងមាំ និងខ្លាំងក្លាបំផុតមិនធ្លាប់មាន ពីប្រជាពលរដ្ឋ ព្រះសង្ឃ មន្ត្រីរាជការថ្នាក់ដឹកនាំ រហូតដល់ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង។

មហាសាមគ្គីជាតិខ្មែរ ជាកម្លាំងចលករដ៏សំខាន់ឈរយ៉ាងស្វាហាប់ ពីក្រោយរាជរដ្ឋាភិបាល និងវីរយុទ្ធជនជាខឿនដ៏រឹងមាំការពារប្រទេសជាតិក្នុងនាមខ្មែរជួយខ្មែរនៅគ្រប់កាលៈទេសៈ ជាមួយរាជរដ្ឋាភិបាល។

រដ្ឋសភា នៅបន្តទទួលអំណោយសប្បុរសធម៌ ហើយនឹងធ្វើការបែងចែកអំណោយទាំងនោះ តាមគោលដៅតម្រូវការ ដោយធ្វើយ៉ាងណាផ្តល់ភាពកក់ក្តៅ និងផ្សារភ្ជាប់ជានិច្ចរវាងយុទ្ធជនជួរមុខ និងពលរដ្ឋជួរក្រោយ៕

សម្តេចរដ្ឋសភាធិបតី ឃួន សុដារី អំពាវនាវពលរដ្ឋឱ្យប្រែក្លាយការឈឺចាប់ពីការឈ្លានពានរបស់បរទេស ទៅជាឱកាសនៃការពង្រឹងខ្លួនគ្រប់វិស័យ

សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា បានអំពាវនាវដល់យុវជន ជាកម្លាំងស្នូលរបស់ប្រទេសជាតិ ក៏ដូចជាពលរដ្ឋទាំងអស់ ឱ្យប្រែក្លាយការឈឺចាប់ពីការឈ្លានពានរបស់ប្រទេសថៃលើអធិបតេយ្យកម្ពុជា ជាឱកាសក្នុងការពង្រឹងចំណេះដឹង ពង្រឹងសមត្ថភាពពង្រឹងសេដ្ឋកិច្ចក្នុងការជំរុញការអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើន ជឿនលឿនទៅមុខបន្ថែមទៀត។ **សម្តេច**បានគូសបញ្ជាក់ថានៅគ្រាលំបាកនេះ យើងមិនត្រូវដេកដួលតាមសភាព ការណ៍នោះឡើយ។ មានន័យថា អ្នកសិក្សាត្រូវខិត

ខំរៀនសូត្រឱ្យកាន់តែខ្លាំងពូកែ អ្នកប្រកបអាជីវកម្មត្រូវខិតខំពង្រីកប្រវ៉ាក់ផលិតកម្មរបស់ខ្លួន ធ្វើយ៉ាងណាឱ្យមានការរីកចម្រើនលូតលាស់ ចូលរួមជាមួយ

មួយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍប្រទេសជាតិ ឱ្យកាន់តែរីកចម្រើនឡើងជាលំដាប់។

ការអំពាវនាវរបស់ **សម្តេចប្រធានរដ្ឋសភា** បានធ្វើឡើងនៅព្រឹកថ្ងៃទី៩ ខែមករា ឆ្នាំ២០២៦ ក្នុងឱកាសអញ្ជើញទទួលអំណោយសប្បុរសធម៌ពីលោក **ម៉ៃ ចាន់នាង** អគ្គនាយកក្រុមហ៊ុន Oudon Express រួមមានថវិកា ១លានរៀល អង្ករ ២តោន ទឹកបរិសុទ្ធ ៥០កេស មី ៥០កេស នំ ៦កេសធំ ចូលរួមជាមួយរាជរដ្ឋាភិបាល តាមរយៈ **សម្តេចប្រធានរដ្ឋសភា** ដើម្បីចែកជូនដល់វីរៈកងទ័ព និងពលរដ្ឋភៀសសឹក។

សម្តេចប្រធានរដ្ឋសភា បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសន្តានចិត្តប្រកបដោយសប្បុរសធម៌របស់ លោកអគ្គនាយក និងសហការីក្រុមហ៊ុន Oudon Express ក៏ដូចជាសប្បុរសជនទាំងអស់ដែលបានបរិច្ចាគនូវធនធានផ្ទាល់ខ្លួន ចូលរួមជាកម្លាំងសប្បុរសធម៌មហាគ្រួសារខ្មែរ ស្របតាមការអំពាវនាវរបស់រាជរដ្ឋាភិបាល។

សម្តេចរដ្ឋសភាធិបតី បានលើកទឹកចិត្តលោក **ម៉ៃ ចាន់នាង** និងសហការីទាំងអស់ដែលជាយុវជន ក៏ដូចជាអ្នកវិនិយោគទាំងអស់ បន្តខិតខំប្រែក្លាយឱកាសពីការឈឺចាប់ ដែលកម្ពុជាកំពុងជួបប្រទះឱ្យក្លាយជាកាលានុវត្តន៍ថ្មី ក្នុងការពង្រឹងមុខរបរ ឬអាជីវកម្មរបស់ខ្លួន ឱ្យកាន់តែសម្បូរបែបឡើងក្នុងការផ្គត់ផ្គង់តម្រូវការក្នុងស្រុក ជំនួសរាល់ផលិតផលនាំចូល។ ការផលិតបាននូវផលិតផលដែលជាតម្រូវការរបស់ប្រជាពលរដ្ឋ មិនត្រឹមជួយឱ្យសេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចគ្រួសារ និងសង្គមជាតិរីកចម្រើនប៉ុណ្ណោះទេ ថែមទាំងធ្វើឱ្យកម្ពុជាមានឯករាជ្យ និងម្ចាស់ការលើគ្រប់វិស័យ។ **សម្តេច**បានសង្កត់ធ្ងន់ថា "សូមយើងទាំងអស់គ្នា ប្តូរការឈឺចាប់របស់យើងនាពេលនេះ ទៅជាភាពរឹងមាំ និងធន់របស់ជាតិយើង"។

រដ្ឋសភា នៅបន្តទទួលអំណោយសប្បុរសធម៌ និងធ្វើការបែងចែកអំណោយទាំងអស់នោះ តាមគោលដៅតម្រូវការ ធ្វើយ៉ាងណាផ្តល់ភាពកក់ក្តៅ និងផ្សារភ្ជាប់ជានិច្ចរវាងពលរដ្ឋជួរក្រោយ និងយុទ្ធជនជួរមុខ៕

រដ្ឋសភា បានអនុម័ត សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីនីតិសមុទ្រ

នៅព្រឹកថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៦ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានបន្តសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា ដើម្បីពិភាក្សា និងអនុម័តសេចក្ដីព្រាងច្បាប់ស្ដីពីការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីនីតិសមុទ្រ។

អង្គរដ្ឋសភាបានធ្វើការពិភាក្សាតាមនីតិវិធីលើសេចក្ដីព្រាងច្បាប់ស្ដីពីការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីនីតិសមុទ្រ មានបីមាត្រា ហើយជាលទ្ធផល អង្គរដ្ឋសភាបានអនុម័តសេចក្ដីព្រាងច្បាប់នេះ ជាឯកច្ឆន្ទ។

អនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីនីតិសមុទ្រឆ្នាំ១៩៨២ ត្រូវបានចុះហត្ថលេខា កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២ នៅទីក្រុងម៉ុងតេហ្គោបៃ ប្រទេសហ្សាម៉ាអ៊ីក ហើយបានចូលជាធរមាននៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៤។ អនុសញ្ញានេះ កំណត់អំពីក្របខ័ណ្ឌគតិយុត្ត នៃការកំណត់ព្រំដែនសមុទ្រ សេរីភាពផ្នែកនាវាចរណ៍តាមផ្លូវសមុទ្រ សិទ្ធិ និងកាតព្វកិច្ចរបស់រដ្ឋភាគី ក្នុងការប្រើប្រាស់លម្ហសមុទ្រ និងសេចក្ដីណែនាំនានា សម្រាប់ការធ្វើធុរកិច្ចកិច្ចការពារបរិស្ថានព្រមទាំងការគ្រប់គ្រងធនធានធម្មជាតិសមុទ្រដ៏សម្បូរបែប។

ការផ្តល់សច្ចាប័នអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ នឹងផ្តល់អត្ថប្រយោជន៍ដល់ព្រះរាជាណាចក្រកម្ពុជា ដែលជាប្រទេសមានសមុទ្រ ដោយទទួលបាននូវក្របខ័ណ្ឌច្បាប់សមុទ្រមួយពេញលេញក្នុងកិច្ចការសមុទ្រ ទទួលបានការការពារតាមច្បាប់សមុទ្រអន្តរជាតិ ទាក់ទងនឹងការគ្រប់គ្រងសមុទ្ររបស់កម្ពុជា និងពង្រឹងតួនាទីកម្ពុជាលើឆាកអន្តរជាតិ តាមរយៈការពង្រីកកិច្ចសហប្រតិបត្តិការ ដោយស្មើមុខក្នុងការគ្រប់គ្រងសមុទ្រ ដោះស្រាយបញ្ហាសមុទ្រជាមួយបណ្តាប្រទេសនានានិងមានសិទ្ធិចូលរួមបោះឆ្នោតជ្រើសរើសសមាសភាពអាជ្ញាធរបាតសមុទ្រអន្តរជាតិ ក៏ដូចជាចៅក្រម តុលាការអន្តរជាតិនីតិសមុទ្រជាដើម ៕

កម្ពុជា-ឥណ្ឌូណេស៊ី ពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរដ្ឋសភាប្រទេសទាំងពីរដើម្បីលើកកម្ពស់ផលប្រយោជន៍ពលរដ្ឋទាំងសងខាង

សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា បានជំរុញសាធារណរដ្ឋឥណ្ឌូណេស៊ី បន្តពង្រឹងពង្រីកទំនាក់ទំនងកិច្ចសហប្រតិបត្តិការរដ្ឋសភាប្រទេសទាំងពីរឱ្យរីកចម្រើន រឹងមាំបន្ថែមទៀតក្នុងការលើកកម្ពស់ផលប្រយោជន៍ប្រជាពលរដ្ឋទាំងសងខាង។

សម្តេចបានគូសបញ្ជាក់ថា រដ្ឋសភាជាស្ថាប័នតំណាងឱ្យពលរដ្ឋ ហេតុដូច្នេះការភ្ជាប់ទំនាក់ទំនងរវាងរដ្ឋសភាប្រទេសទាំងពីរ គឺជាការតភ្ជាប់ទំនាក់ទំនងពលរដ្ឋនិងពលរដ្ឋ ដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់នៅក្នុងការពង្រឹងពង្រីកវិស័យនានា ដូចជាពាណិជ្ជកម្ម សេដ្ឋកិច្ច ទេសចរណ៍ និងអប់រំ ជាដើម។

សម្តេចប្រធានរដ្ឋសភាបានលើកសំណើបែបនេះ ក្នុងឱកាសអនុញ្ញាតជូន ឯកឧត្តម **សាន់តូ ដាម៉ូស៊ូម៉ាតូ** (Santo Darmosumarto) ឯកអគ្គរដ្ឋទូតសាធារណរដ្ឋឥណ្ឌូណេស៊ីប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបប់អាណត្តិ ចូលជួបពិភាក្សាការងារ និងជម្រាបលា នៅវិមានរដ្ឋសភា ព្រឹកថ្ងៃទី ២២ ខែមករា ឆ្នាំ២០២៦។

នៅក្នុងឱកាសនោះ **សម្តេចប្រធានរដ្ឋសភា** បានវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលជាច្រើន ដែលឯកឧត្តមឯកអគ្គរដ្ឋទូតសម្រេចបានគួរជាទីមោទនៈ ក្នុងការរួមចំណែកលើកកម្ពស់ទំនាក់ទំនងកម្ពុជា-ឥណ្ឌូណេស៊ី ឱ្យកាន់តែជិតស្និទ្ធ ស៊ីជម្រៅ និងទូលំទូលាយ ពិសេស ការផ្សារភ្ជាប់ផ្នែកធុរកិច្ច ការផ្លាស់ប្តូរវប្បធម៌ និងការជំរុញទំនាក់ទំនងរវាងប្រជាជននិងប្រជាជនដែលជាមូលដ្ឋានគ្រឹះសំខាន់នៃចំណងមិត្តភាពរវាងប្រទេសទាំងពីរ។

ឯកឧត្តម **សាន់តូ ដាម៉ូស៊ូម៉ាតូ** បានអរគុណយ៉ាងជ្រាលជ្រៅជូន **សម្តេចប្រធានរដ្ឋសភា** ដែលបានចំណាយពេលវេលាដ៏មមាញឹក អនុញ្ញាតដល់ឯកឧត្តមបានចូលជួបពិភាក្សាការងារ និងជម្រាបលានាឱកាសនេះ និងអរគុណរដ្ឋសភាផងដែរ ដែលបានផ្តល់កិច្ចសហការយ៉ាងជិតស្និទ្ធជាមួយស្ថានទូតឥណ្ឌូណេស៊ីប្រចាំក្រុងភ្នំពេញ ធ្វើឱ្យបេសកកម្មការទូតរបស់ ឯកឧត្តមទទួលបានជោគជ័យ។

ឯកឧត្តមឯកអគ្គរដ្ឋទូត បានយល់ស្របជាមួយ **សម្តេចប្រធាន** ពីសារៈសំខាន់នៃទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរដ្ឋសភាប្រទេសទាំងពីរក្នុងការជំរុញនិងលើកកម្ពស់ផលប្រយោជន៍ដល់ពលរដ្ឋទាំងសងខាង។ ឯកឧត្តមបានគូសបញ្ជាក់ថា នៅក្នុងអាណត្តិបេសកកម្មការទូតនៅកម្ពុជា ឯកឧត្តមបានខិតខំលើកកម្ពស់កិច្ចសហប្រតិបត្តិការប្រទេសទាំងពីរ ទាំងស្ថាប័ននីតិប្បញ្ញត្តិ និងប្រតិបត្តិដែលក្នុងនោះវិស័យពាណិជ្ជកម្មកម្ពុជា-ឥណ្ឌូណេស៊ីបានកើនឡើងដល់ជាង ១ពាន់លានដុល្លារ។

ឯកឧត្តមបានសម្តែងនូវការពេញចិត្តចំពោះការរីកចម្រើនជាបន្តបន្ទាប់នៃទំនាក់ទំនងប្រទេស



ទាំងពីរ តាមរយៈការបន្តផ្លាស់ប្តូរទស្សនកិច្ចគ្រប់កម្រិតទៅវិញទៅមក ជាពិសេស ទស្សនកិច្ចរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៅប្រទេសឥណ្ឌូណេស៊ីក្នុងឆ្នាំ២០២៥ និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៅឆ្នាំ២០២៥។

ឥណ្ឌូណេស៊ីជាមិត្តដ៏ល្អរបស់កម្ពុជា និងជាដៃគូដ៏គួរទុកចិត្ត។ បំណងមិត្តភាពកិច្ចសហប្រតិបត្តិការប្រទេសទាំងពីរ ឈរលើភាពស្មោះត្រង់ ជឿទុកចិត្តគ្នានិងការផ្តល់ផលប្រយោជន៍ទៅវិញទៅមក។ ឥណ្ឌូណេស៊ីបានរួមចំណែកស្វែងរកសុខសន្តិភាព និងបានគាំទ្រដល់ការអភិវឌ្ឍនៅកម្ពុជា រហូតមក។

សម្តេចរដ្ឋសភាធិបតី **ឃួន សុដារី** ក៏បានអរគុណចំពោះអនុព័ន្ធយោធាឥណ្ឌូណេស៊ី ដែលបានចូលរួមយ៉ាងសកម្មជាមួយក្រុមអ្នកសង្កេតការណ៍អាស៊ាន (AOT) ក្នុងការធានាដល់ការអនុវត្តបទឈប់បាញ់ប្រកបដោយប្រសិទ្ធភាព ធ្វើយ៉ាងណាឱ្យស្ថានការណ៍ព្រំដែនកម្ពុជា-ថៃ វិលទៅរកប្រក្រតីភាពវិញ ដែលជាបំណងប្រាថ្នារបស់ពលរដ្ឋប្រទេសទាំងពីរ ក៏ដូចជាបំណងប្រាថ្នារបស់អាស៊ាន និងពិភពលោកផងដែរ។

សម្តេចប្រធានរដ្ឋសភា បានគូសបញ្ជាក់ថា ក្នុងនាមជាប្រទេសធំជាងគេក្នុងតំបន់អាស៊ីអាគ្នេយ៍ ឥណ្ឌូណេស៊ី បានបង្ហាញនូវតួនាទីជាអ្នកដឹកនាំគំរូ តាមរយៈការប្រកាន់ខ្ជាប់ នូវការគោរពបទដ្ឋានអន្តរជាតិ និងការគោរពធម្មនុញ្ញអាស៊ាន ដែលទាំងនេះជាស្មារតីស្នូល និងជាគោលបំណងពិតប្រាកដរបស់អាស៊ាន ដែលសមាជិកទាំងអស់មិនថាជាប្រទេសតូចឬធំ មានសិទ្ធិស្មើគ្នា គោរពបូរណភាពទឹកដី និងអធិបតេយ្យនៃប្រទេសនីមួយៗ។

ឯកឧត្តម **សាន់តូ ដាម៉ូស៊ូម៉ាតូ** បានគូសបញ្ជាក់ថា ឥណ្ឌូណេស៊ីនៅបន្តចូលរួមយ៉ាងសកម្មក្នុងការបញ្ចប់ជម្លោះព្រំដែនកម្ពុជា និងថៃដោយសន្តិវិធី។

សម្តេចប្រធានរដ្ឋសភា និងឯកឧត្តមឯកអគ្គរដ្ឋទូត បានយល់ស្របគ្នាថា សង្គ្រាមមិនមានអ្នកឈ្នះនោះឡើយ តែផ្ទុយទៅវិញមានតែសន្តិភាព ដែលភាគីទាំងពីរឈ្នះ-ឈ្នះទាំងអស់គ្នា៕

សាធារណរដ្ឋកូរ៉េ បន្តលើកកម្ពស់ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ ជាមួយកម្ពុជាទាំងស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ

នៅក្នុងឱកាសចូលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយ សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា ឯកឧត្តម **គីម ឆាងយ៉ុង** (KIM CHANGYONG) ឯកអគ្គរដ្ឋទូតទើបតែងតាំងថ្មីនៃសាធារណរដ្ឋកូរ៉េប្រចាំកម្ពុជាបានគូសបញ្ជាក់ថា សាធារណរដ្ឋកូរ៉េនឹងបន្តពង្រឹងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ ជាមួយកម្ពុជា ទាំងក្របខ័ណ្ឌស្ថាប័ននីតិប្បញ្ញត្តិ និងស្ថាប័ននីតិប្រតិបត្តិ។

ក្នុងជំនួបពិភាក្សាការងារនៅវិមានរដ្ឋសភា នាព្រឹកថ្ងៃទី២២ ខែមករា ឆ្នាំ២០២៦ **សម្តេចប្រធានរដ្ឋសភា** បានសម្តែងនូវក្តីសោមនស្សរីករាយ និងស្វាគមន៍យ៉ាងកក់ក្តៅចំពោះ ឯកឧត្តម **គីម ឆាងយ៉ុង** ដោយគូសបញ្ជាក់ថា ជាមួយបទពិសោធន៍យ៉ាងទូលំទូលាយ ចំណេះដឹងជ្រៅជ្រះ និងឆន្ទៈដ៏មោះមុត ក្នុងបេសកកម្មការទូតនៅកម្ពុជានេះ នឹងសម្រេចបាននូវសមិទ្ធផលថ្មីៗបន្ថែមទៀត ដែលនឹងរួមចំណែកធ្វើឱ្យទំនាក់ទំនង កិច្ចសហប្រតិបត្តិការទ្វេភាគីរវាងប្រទេសទាំងពីរ កាន់តែមានភាពជិតស្និទ្ធ រឹងមាំ ស៊ីជម្រៅ និងទូលំទូលាយឈានដល់កម្រិតខ្ពស់ថ្មីមួយ នាំមកនូវប្រយោជន៍ដ៏ឧត្តុង្គឧត្តមជូនប្រជាជន និងប្រទេសទាំងពីរ។

ភាពជាដៃគូយុទ្ធសាស្ត្រកម្ពុជា-សាធារណរដ្ឋកូរ៉េ ផ្អែកលើការជឿទុកចិត្តគ្នា ការគោរពគ្នា ការយល់យោគគ្នា និងផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក ព្រមទាំងការប្តេជ្ញាចិត្តរួមគ្នា ដើម្បីសម្រេចបាននូវអត្ថប្រយោជន៍សម្រាប់ប្រទេសជាតិ និងប្រជាជនទាំងសងខាង។

សម្តេចរដ្ឋសភាធិបតី បានអរគុណដល់សាធារណរដ្ឋកូរ៉េដែលបានចូលរួមស្វែងរកសន្តិភាព និងបានគាំទ្រដល់ការអភិវឌ្ឍរបស់កម្ពុជារហូតមក។ **សម្តេចរដ្ឋសភាធិបតី** បានស្នើ ឯកឧត្តមឯកអគ្គរដ្ឋទូត បន្តជំរុញអ្នកវិនិយោគ អ្នកទេសចរ ពីសាធារណរដ្ឋកូរ៉េមកកាន់កម្ពុជាបន្ថែមទៀត។

"អរិយធម៌បុរាណ នៃប្រទេសយើងទាំងពីរបានបញ្ជាក់ពីសក្តានុពល សម្រាប់កិច្ចសហប្រតិបត្តិការឱ្យកាន់តែស៊ីជម្រៅ តាមរយៈការផ្លាស់ប្តូរវប្បធម៌ អប់រំ និងទេសចរណ៍ នៃប្រទេសទាំងពីរ"។



ជាមួយគ្នានោះ **សម្តេច**ក៏បានស្នើដល់សាធារណរដ្ឋកូរ៉េ ជួយផ្តល់ការបណ្តុះបណ្តាលជំនាញបច្ចេកវិទ្យាដល់មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភា ដើម្បីផ្តល់សេវាកាន់តែប្រសើរ ជូនតំណាងរាស្ត្រ។





សម្តេចប្រធានរដ្ឋសភា បានគូសបញ្ជាក់ថា រាជរដ្ឋាភិបាលអាណត្តិទី៧ ដឹកនាំដោយ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** បានកំណត់ច្បាស់ នៅក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ គឺ "មនុស្ស" ជាកត្តាទី១ និងចម្បងបំផុតក្នុងការកែទម្រង់ និងអភិបាលកិច្ច។

ឯកឧត្តម **គីម ឆាងយ៉ុង** បានថ្លែងអំណរគុណចំពោះ **សម្តេចប្រធានរដ្ឋសភា** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ទទួលជួបពិភាក្សាការងារជាមួយ ឯកឧត្តម នាឱកាសនេះ។ ឯកឧត្តម បានជម្រាប **សម្តេច** ពីគម្រោងអភិវឌ្ឍន៍ជាច្រើនដែលសាធារណរដ្ឋកូរ៉េ បាននិងកំពុងសហការជាមួយកម្ពុជា តាមរយៈកម្មវិធីអភិវឌ្ឍន៍ផ្លូវការរបស់សាធារណរដ្ឋកូរ៉េ (ODA)។ ឯកឧត្តមបានថ្លែងកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការបង្ក្រាបបទល្មើសឆ្លងដែន បទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់ប្រភេទ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលប្រការនេះ បានផ្តល់ភាពកក់ក្តៅ និងទំនុកចិត្តយ៉ាងខ្លាំងដល់ពលរដ្ឋសាធារណរដ្ឋកូរ៉េក្នុងការធ្វើដំណើរមកកម្ពុជា។ ឯកឧត្តមបានបញ្ជាក់ថា រដ្ឋាភិបាលកូរ៉េត្រៀមខ្លួនជួយដល់កម្ពុជាក្នុងការកសាង និងលើកកម្ពស់សមត្ថភាពប្រយុទ្ធប្រឆាំងនឹងបទល្មើសឆ្លងដែន និងការឆបោកតាមប្រព័ន្ធអនឡាន។

ជាមួយគ្នានោះ ឯកឧត្តមឯកអគ្គរដ្ឋទូតបានស្នើ **សម្តេចប្រធានរដ្ឋសភា** ក៏ដូចជារដ្ឋសភាកម្ពុជាក្នុងការគាំទ្របេក្ខជនពីសភាសាធារណរដ្ឋកូរ៉េ ជាអគ្គលេខាធិការ អាណត្តិថ្មី របស់សហភាពអន្តរសភា (IPU)។ ឯកអគ្គរដ្ឋទូតក៏បានសម្តែងនូវសមានចិត្តយ៉ាងជ្រាលជ្រៅ ជាមួយប្រជាពលរដ្ឋកម្ពុជា ដែលទទួលរងផលប៉ះពាល់ពីជម្លោះព្រំដែនកម្ពុជា-ថៃ។ ហេតុការណ៍នេះបានបណ្តាលឱ្យមានពលរដ្ឋបាត់បង់អាយុជីវិត ខូតខាតទ្រព្យសម្បត្តិ និងត្រូវចាកចេញពីលំនៅឋាន មិនអាចប្រកបរបរចិញ្ចឹមជីវិត ក្មេងៗមិនបានទៅសាលារៀនជាដើម។

ឯកឧត្តមឯកអគ្គរដ្ឋទូតបានគូសបញ្ជាក់បន្ថែមថា សាធារណរដ្ឋកូរ៉េកំពុងរៀបចំផ្តល់ជំនួយជាទឹកប្រាក់ ៥0ម៉ឺនដុល្លារ តាមរយៈអង្គការ UNICEF ប្រចាំកម្ពុជា ដើម្បីចូលរួមដោះស្រាយទុក្ខលំបាកទាំងនោះ។

សម្តេចប្រធានរដ្ឋសភា បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ សាធារណរដ្ឋកូរ៉េ ដែលបានចូលរួមសហការជាមួយកម្ពុជា ក្នុងការបង្ក្រាបបទល្មើសឆ្លងដែនគ្រប់ប្រភេទ ជាពិសេស បទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា នាពេលថ្មីៗនេះ៕

សម្តេចរដ្ឋសភាធិបតី ឃួន សុដារី អញ្ជើញចូលរួមពិធីសូត្រមន្តក្រុងពាលី ចម្រើនព្រះបរិត្តឡើងអគារថ្មី «វិមានសាមគ្គីភាព» នៃព្រឹទ្ធសភា

សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា បានអញ្ជើញចូលរួមពិធីសូត្រមន្តក្រុងពាលី ចម្រើនព្រះបរិត្ត សុំសេចក្តីសុខចម្រើនឡើងអគារថ្មី «វិមានសាមគ្គីភាព» នៃព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា នៅវិមានព្រឹទ្ធសភា នាព្រឹកថ្ងៃសុក្រ ទី២៣ ខែមករា ឆ្នាំ២០២៦។

អគារ «វិមានសាមគ្គីភាព» បានបើកការដ្ឋានសាងសង់កាលពីថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៤ មានបណ្តោយប្រវែង ៧៩ម៉ែត្រ និងទទឹងប្រវែង ៤៧ ម៉ែត្រ មានកម្ពស់បួនជាន់ ជាអគារបំពេញការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជាសាលប្រជុំព្រឹទ្ធសភា ព្រមទាំងជាកន្លែងទទួលបដិសណ្ឋារកិច្ចគណៈប្រតិភូនានា។ «វិមានសាមគ្គីភាព» ជាសមិទ្ធផលថ្មី និងជាប្រវត្តិសាស្ត្រមួយទៀត ដែលបានលេចរូបរាងឡើងក្រោមម្លប់សុខសន្តិភាពនិងក្រោមការដឹកនាំផ្ទាល់របស់ សម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា។ បន្ទាប់ពីសូត្រមន្តក្រុងពាលី ចម្រើនព្រះបរិត្តហើយនោះ អគារថ្មីនៃព្រឹទ្ធសភាគ្រោងនឹងសម្ពោធដាក់ឱ្យប្រើប្រាស់ក្នុងពេលឆាប់ៗនេះ ក្រោមព្រះរាជធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា៕



ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប
អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការឥស្សរិយយសរដ្ឋសភា



ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១ នៃរដ្ឋសភា និងជាប្រធានគណៈកម្មាធិការឥស្សរិយយសរដ្ឋសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការឥស្សរិយយស ដើម្បីពិនិត្យវឌ្ឍនភាពការងារកន្លងមក និងវាយតម្លៃការផ្តល់គ្រឿងឥស្សរិយយសជូន តំណាងរាស្ត្រនីតិកាលទី៧ លើកទី១ នៅវិមានរដ្ឋសភា នាព្រឹកថ្ងៃទី ៨ ខែមករា ឆ្នាំ២០២៦។

ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត មានប្រសាសន៍ថា ក្នុងនីតិកាលទី៧នេះ គណៈកម្មាធិការឥស្សរិយយស បានប្រជុំពិភាក្សាចំនួន ៤ដង។ កិច្ចប្រជុំទាំងនេះ បង្ហាញពីការយកចិត្តទុកដាក់ និងអនុវត្តការងារយ៉ាងហ្មត់ចត់ បន្ទាប់ពីទទួលបានការតែងតាំងជាប្រធានគណៈកម្មាធិការឥស្សរិយយសរដ្ឋសភាពី សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា ដើម្បីត្រួតពិនិត្យ និងផ្តល់គ្រឿងឥស្សរិយយសជូន តំណាងរាស្ត្រ នីតិកាលទី៧ នៃរដ្ឋសភា ជាលើកទី១។ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត**បានបន្តថា យោងច្បាប់លក្ខន្តិកៈតំណាងរាស្ត្រ និងបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា បានចែងថា តំណាងរាស្ត្រក្នុងតំណែងទាំងអស់ នឹងត្រូវទទួលគ្រឿងឥស្សរិយយសពីរដង ក្នុងមួយអាណត្តិ។

ក្នុងឱកាសនោះ ឯកឧត្តម **ឃួន ដារិទ្ធ** អគ្គលេខាធិការងរដ្ឋសភា បានមានប្រសាសន៍ថា គណៈកម្មាធិការឥស្សរិយយស បានប្រជុំត្រួតពិនិត្យការងារ លើនីតិវិធី និងលក្ខខណ្ឌ នៃការផ្តល់គ្រឿងឥស្សរិយយស ហើយជាលទ្ធផល គឺបានទទួលឯកសារបំពេញគ្រឿងឥស្សរិយយស របស់សមាជិកសមាជិការដ្ឋសភាចំនួន ៩០រូប(តំណាងរាស្ត្រសំណូមពរ ៥១រូប) និងបានរៀបចំតារាងរាយនាមតំណាងរាស្ត្រ ១២៥រូប រួចរាល់ ដោយទទួលបានការឯកភាព ១០០% លើនីតិវិធី និងលក្ខខណ្ឌ នៃការផ្តល់គ្រឿងឥស្សរិយយស៕

ឯកឧត្តម ខេង សួត ផ្តល់អនុសាសន៍ដល់យុវជនត្រូវបន្តខិតខំរៀនសូត្រ អភិវឌ្ឍសមត្ថភាព ចូលរួមកសាងមិត្តភាព និងសហប្រតិបត្តិការអន្តរជាតិ

ឯកឧត្តម **ខេង សួត** អនុប្រធានទី២ រដ្ឋសភាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចប្រធានរដ្ឋសភា** នាព្រឹកថ្ងៃទី៦ ខែមករា ឆ្នាំ២០២៦ នៅវិមានរដ្ឋសភា បានទទួលជួបសំណេះសំណាល និងផ្តល់អនុសាសន៍ដល់ប្រតិភូសមាគមនាវាយុវជនអាស៊ីអាគ្នេយ៍កម្ពុជា-ជប៉ុន ដើម្បីជាមូលដ្ឋានក្នុងការចូលរួមកម្មវិធីនាវាយុវជនអាស៊ីអាគ្នេយ៍ និងជប៉ុន (SSEAYP) រយៈពេល ២៦ថ្ងៃ ទៅកាន់ប្រទេសសិង្ហបុរី និងប្រទេសជប៉ុន។ ក្នុងឱកាសនោះ **ឯកឧត្តម** បានរំលឹកពីអតីតកាល ដែលយុវជនជំនាន់ក្រោយត្រូវដឹងអំពីប្រវត្តិសាស្ត្រខ្មែរ ដែលធ្លាប់ឆ្លងកាត់សង្គ្រាមរ៉ាំរ៉ៃ និងធ្លាក់ចូលក្នុងរបបប្រល័យពូជសាសន៍ ហើយបានសម្លាប់ប្រជាជនអស់ជាច្រើនលាននាក់។ សន្តិភាព និងការអភិវឌ្ឍដែលកម្ពុជាមានដូចសព្វថ្ងៃនេះគឺកើតចេញពីការបូជាសាច់ស្រស់ឈាមស្រស់របស់ឥស្សរជនជាតិជាន់ខ្ពស់របស់យើង ដែលតស៊ូផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត នាថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ ប្រជាពលរដ្ឋត្រូវមានការចងចាំជានិច្ច នូវមហាសោកនាដកម្មក្នុងរបបដ៏ខ្មៅងងឹតរយៈពេល ៣ឆ្នាំ ៨ខែ ២០ថ្ងៃ និងផ្តន្ទាទោសចំពោះបុគ្គលទាំងឡាយណា ដែលបដិសេធមិនទទួលស្គាល់ការពិត ចំពោះប្រវត្តិសាស្ត្រដ៏សែនជូរចត់បំផុត ដែលបានកើតឡើងនៅកម្ពុជា។

ឯកឧត្តមអនុប្រធានទី២ បានពន្យល់ពីតួនាទីសំខាន់របស់យុវជន ក្នុងការរក្សាបានសាមគ្គីភាពពិសេស ក្នុងបរិបទដែលបញ្ហាព្រំដែនកំពុងប្រឈម ហើយត្រូវជឿជាក់លើរដ្ឋាភិបាលក្នុងដោះស្រាយតាមយន្តការការទូតនិងច្បាប់អន្តរជាតិ។

ឯកឧត្តមបានផ្តាំផ្ញើដល់ប្រតិភូនាវាយុវជនអាស៊ីអាគ្នេយ៍ ត្រូវប្រកាន់ភ្ជាប់សាមគ្គីផ្ទៃក្នុង រក្សាឥរិយាបទ និងតម្លៃជាតិ ផ្សព្វផ្សាយអំពីវប្បធម៌ជាតិ ចូលរួមលើកកម្ពស់សន្តិភាព និងការរួមរស់ជាមួយគ្នាដោយសន្តិសហវិជ្ជមាន ជាពិសេស ត្រូវចូលរួមគាំទ្រការដឹកនាំរបស់រាជរដ្ឋាភិបាល ដើម្បីបន្តរួមចំណែកអភិវឌ្ឍជាតិមាតុភូមិយើង៕

តំណាងសម្តេចប្រធានរដ្ឋសភា និងមូលនិធិសប្បុរសធម៌ ប៊ែលធី នាំយកអំណោយជូនវីរៈកងទ័ពជួរមុខ និងជនភៀសសឹក នៅខេត្តឧត្តរមានជ័យ

តំណាងដ៏ខ្ពង់ខ្ពស់សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា ដឹកនាំដោយលោកជំទាវ **និន សាផុន** ប្រធានគណៈកម្មការទី៩ នៃរដ្ឋសភា និងឯកឧត្តមបណ្ឌិត **លី ឆេង** អនុប្រធានគណៈកម្មការ និងជាស្ថាបនិកអគ្គនាយកប៊ែលធីគ្រុប រួមជាមួយឯកឧត្តម លោកជំទាវ សមាជិក សមាជិកាគណៈកម្មការ នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២៦ បាននាំយកអំណោយដ៏ថ្លៃថ្លា របស់ **សម្តេចប្រធានរដ្ឋសភា** និងគណៈកម្មការទី៩ ព្រមទាំងមូលនិធិសប្បុរសធម៌របស់ ប៊ែលធី (BELTEI Charity) ប្រគល់ជូនវីរៈកងទ័ពជួរមុខ ពលរដ្ឋភៀសសឹក ក្រុមគ្រូពេទ្យ និងសាលារៀនបណ្តោះអាសន្នក្នុងជំរំសុវត្ថិភាព វត្តបាត់ថ្កៅ ខេត្តឧត្តរមានជ័យ។

ពិធីប្រគល់អំណោយនេះ ទទួលបានការស្វាគមន៍យ៉ាងកក់ក្តៅ និងយកចិត្តទុកដាក់ពី ឯកឧត្តម **មាន ចាន់យ៉ាដា** អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ និងមានការអញ្ជើញចូលរួមពីមន្ត្រីជំនួយការគណៈកម្មការទី៩ ព្រមទាំងគណៈគ្រប់គ្រង បុគ្គលិក សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស-និស្សិតប៊ែលធីជាច្រើននាក់ទៀត។

ក្នុងឱកាសពិធីប្រគល់អំណោយមនុស្សធម៌នេះ ឯកឧត្តមបណ្ឌិត **លី ឆេង** បានថ្លែងអំណរគុណចំពោះការលះបង់ដ៏ធំធេងរបស់វីរៈកងទ័ពនិងបានចូលរួមរំលែកការលំបាកជាមួយបងប្អូនជនភៀសសឹកផងដែរ។ ឯកឧត្តមបណ្ឌិត បានជម្រាបជូនថា រដ្ឋសភាកម្ពុជា ជាពិសេសតំណាងរាស្ត្រទាំងអស់ តែងគិតគូរពីសុខទុក្ខរបស់វីរៈកងទ័ព ដោយស្មារតីរួមសាមគ្គីគ្នា «ខ្មែរតែមួយ»។ ជាមួយស្មារតីនេះ ប្រជាជនកម្ពុជាទូទាំងប្រទេស គ្រប់មជ្ឈដ្ឋាន និងសប្បុរសជននានា រួមទាំងគណៈគ្រប់គ្រង បុគ្គលិក សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត និងសិស្សានុសិស្សនៃសាលាប៊ែលធីអន្តរជាតិគ្រប់ទីតាំង បានចូលរួមបរិច្ចាគថវិកា សម្ភារ និងគ្រឿងឧបភោគបរិភោគ ជូនដល់វីរៈកងទ័ពកំពុងឈរជើងនៅតាមសមរភូមិមុខ គ្រួសារវីរៈកងទ័ព និងជនភៀសសឹក ដែលកំពុងរងផលប៉ះពាល់ពីការឈ្លានពានដ៏ឃោរឃៅ និងអមនុស្សធម៌របស់ឃោជាថៃ។

ថ្លែងក្នុងពិធីនេះ លោកជំទាវ **និន សាផុន** បាននាំយកនូវទឹកចិត្តដ៏សប្បុរសរបស់ **សម្តេចប្រធានរដ្ឋសភា** ដែលជានិច្ចកាល តែងយកចិត្តទុកដាក់ និងព្រួយបារម្ភពីសុខទុក្ខរបស់ក្រុមគ្រួសារវីរៈកងទ័ព

រួមជាមួយការផ្តាំផ្ញើសួរសុខទុក្ខ និងការគោរពដឹងគុណ ចំពោះវីរភាពដ៏អង់អាចក្លាហានរបស់វីរយុទ្ធជន ដែលបានការពារបូរណភាពជាតិ មាតុភូមិ និងប្រជាជន។ លោកជំទាវ បានផ្តាំផ្ញើដល់ប្រជាជនទាំងអស់ ត្រូវបន្តជឿជាក់លើការដឹកនាំដ៏ត្រឹមត្រូវរបស់ សម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងសម្តេចធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី។

បន្ទាប់មក លោកជំទាវប្រធានក៏បានបន្តដឹកនាំប្រតិភូជួបសំណេះសំណាល និងនាំយកអំណោយជូនដល់ក្រុមគ្រូពេទ្យប្រចាំការនៅជំរំសុវត្ថិភាពវត្តបាត់ថ្មៅ ព្រមទាំងលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សចំនួន ៤៧៣នាក់ រួចបន្តទស្សនាសកម្មភាពដាំដុះបន្លែ នៅសួនបន្លែជនភៀសសឹកដែលជាគំនិតផ្តួចផ្តើមរបស់ លោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត**។

គណៈប្រតិភូគណៈកម្មការទី៩ និងមូលនិធិសប្បុរសធម៌ប៉ៃលិធី បានប្រគល់អំណោយដ៏ថ្លៃថ្លារបស់ **សម្តេចប្រធានរដ្ឋសភា** ជូនវីរៈកងទ័ព និងជនភៀសសឹក។

សម្រាប់វីរៈកងទ័ពមានថវិកាចំនួន ៧០លានរៀល អង្ករ ៦តោន ត្រីខ ៥០០យួរ មីជាតិ ៥០០កេស ទឹកបរិសុទ្ធ ៥០០កេស ឆៃប៉ូវផ្អែម ៥០០គីឡូ ផ្អកសាច់ជ្រូក ១ធុង ត្រសក់បារ ១ធុង អាវរងា ៨០០អាវ ថ្នាំពេទ្យ ១ឡាំង និងនំ ៣០កេស។

គណៈប្រតិភូ ក៏បានចែកអំណោយជូនជនភៀសសឹកចំនួន ៣០០គ្រួសារ ដោយមួយគ្រួសារទទួលបានថវិកា ៥ម៉ឺនរៀល អង្ករ ១០គីឡូក្រាម ទឹកបរិសុទ្ធ ១កេស សម្ភារប្រើប្រាស់ និងគ្រឿងឧបភោគបរិភោគ ១កញ្ចប់៕

គណៈកម្មការជំនាញរដ្ឋសភា និងតំណាងរាជរដ្ឋាភិបាល ប្រជុំពិនិត្យសិក្សា និងប្រមូលធាតុចូលស្តីពី សេចក្តីព្រាងច្បាប់ស្តីពីនីតិសមុទ្រ

អន្តរគណៈកម្មការជំនាញរបស់រដ្ឋសភា ដឹកនាំដោយ ឯកឧត្តម **សួស យ៉ារ៉ា** ប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន (គ៥) ដោយមានការញ្ជើញចូលរួមពី ឯកឧត្តម **កែប ជុតិមា** ប្រធានគណៈកម្មការមហាផ្ទៃ ការពារជាតិ មុខងារសាធារណៈ និងកិច្ចការព្រំដែន (គ៤) និងឯកឧត្តម **អង្គ វង្ស វឌ្ឍនា** ប្រធានគណៈកម្មនីតិកម្ម និងយុត្តិធម៌ (គ៦) នៃរដ្ឋសភា ព្រមទាំង ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាគណៈកម្មការជំនាញទាំង១០ នៃរដ្ឋសភា បានជួបប្រជុំដើម្បីពិនិត្យសិក្សា លើសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ នាព្រឹកថ្ងៃទី១២ ខែមករា ឆ្នាំ២០២៦ នៅវិមានរដ្ឋសភា។

តំណាងរាជរដ្ឋាភិបាលដឹកនាំដោយ ឯកឧត្តម **ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឯកឧត្តម **ឡាំ ជា** រដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការព្រំដែន ព្រមទាំង ឯកឧត្តមតំណាងក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី និងឯកឧត្តមតំណាងក្រសួងយុត្តិធម៌។

ឯកឧត្តម **សួស យ៉ារ៉ា** ប្រធានអង្គប្រជុំ បានមានប្រសាសន៍ថា កិច្ចប្រជុំពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់នេះ ធ្វើឡើងក្នុងគោលបំណងចែករំលែក និងប្រមូលនូវធាតុចូលដើម្បីពិនិត្យរួមគ្នា ធ្វើយ៉ាងណាឱ្យសេចក្តីព្រាងច្បាប់នេះ អនុម័តចេញទៅទទួលបាននូវឧត្តមប្រយោជន៍ជូនប្រទេសជាតិ និងប្រជាជន។

ឯកឧត្តម **ប្រាក់ សុខុន** បានមានប្រសាសន៍ជម្រាបជូន ឯកឧត្តមប្រធានអង្គប្រជុំ ក៏ដូចជាអន្តរគណៈកម្មការជំនាញរបស់រដ្ឋសភាថា អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ ឆ្នាំ១៩៨២ ត្រូវបានចុះហត្ថលេខា កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២ នៅទីក្រុងម៉ុងតេហ្គោបេ ប្រទេសហ្សាម៉ាអ៊ីក និងចូលជាធរមាននៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៤។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានបន្តទៀតថា អនុសញ្ញានេះ បានកំណត់អំពីក្របខ័ណ្ឌគតិយុត្តនៃការកំណត់ព្រំដែនសមុទ្រ សេរីភាពផ្នែកនាវាចរណ៍តាមផ្លូវសមុទ្រ សិទ្ធិ និងកាតព្វកិច្ចរបស់រដ្ឋភាគីក្នុងការប្រើប្រាស់លម្ហសមុទ្រ និងសេចក្តីណែនាំនានា សម្រាប់ការធ្វើធុរកិច្ច កិច្ចការពារបរិស្ថាន ព្រមទាំងការគ្រប់គ្រងធនធានធម្មជាតិសមុទ្រដ៏

សម្បូរបែប ដែលចងក្រងនូវវិធានទំនៀមទម្លាប់អន្តរជាតិក្នុងវិស័យសមុទ្រ ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធនឹងអាជ្ញាធរបាតសមុទ្រអន្តរជាតិ និងយន្តការដោះស្រាយវិវាទនីតិសមុទ្រ។ ម្យ៉ាងទៀត ការផ្តល់សច្ចាប័នអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ នឹងផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់ព្រះរាជាណាចក្រកម្ពុជាដូចជា៖

- ទទួលបាននូវក្របខ័ណ្ឌច្បាប់សមុទ្រមួយពេញលេញសម្រាប់កិច្ចការសមុទ្រ ក្នុងនាមជាប្រទេសជាប់សមុទ្រ។

- ទទួលបានការការពារតាមច្បាប់សមុទ្រអន្តរជាតិទាក់ទងនឹងការគ្រប់គ្រងសមុទ្ររបស់កម្ពុជា ដូចជាការគ្រប់គ្រង និងការអភិរក្សបរិស្ថានសមុទ្រ ការធ្វើអាជីវកម្មលើធនធានសមុទ្រ និងការស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រជាដើម។

- ពង្រឹងតួនាទីកម្ពុជាលើឆាកអន្តរជាតិ តាមរយៈការពង្រីកកិច្ចសហប្រតិបត្តិការដោយស្មើមុខក្នុងការគ្រប់គ្រងសមុទ្រ និងការដោះស្រាយបញ្ហាសមុទ្រជាមួយបណ្តាប្រទេសនានា និងមានសិទ្ធិចូលរួមបោះឆ្នោតជ្រើសរើស សមាសភាពអាជ្ញាធរបាតសមុទ្រអន្តរជាតិ ក៏ដូចជាចៅក្រមតុលាការអន្តរជាតិនីតិសមុទ្រផងដែរ។

- ទទួលបាននូវកិច្ចសហប្រតិបត្តិការ និងជំនួយបច្ចេកទេសរួមទាំងជំនួយផ្នែកច្បាប់អន្តរជាតិពាក់ព័ន្ធនឹងការការពារ ការអភិរក្សបរិស្ថានសមុទ្រ និងការផ្ទេរបច្ចេកវិទ្យាពីរដ្ឋភាគី និងស្ថាប័នអន្តរជាតិនានាពាក់ព័ន្ធនឹងអនុសញ្ញានេះ។

ក្រោយពីបានពិភាក្សាយ៉ាងល្អិតល្អន់ជាមួយតំណាងរាជរដ្ឋាភិបាល ដោយមានការសួរ និងបកស្រាយបំភ្លឺរួចមក ឯកឧត្តម **សួស យ៉ារ៉ា** បានថ្លែងនូវអំណរគុណ និងកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ប៉ិនប្រសប់របស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីកម្ពុជា ព្រមទាំងឯកឧត្តម **ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលបានខិតខំយកចិត្តទុកដាក់ធ្វើសេចក្តីព្រាងច្បាប់នេះឡើងដើម្បីរក្សាសុខសុវត្ថិភាព ក្នុងដែនសមុទ្ររបស់ព្រះរាជាណាចក្រកម្ពុជា នៅលើឆាកអន្តរជាតិ។

សេចក្តីព្រាងច្បាប់នេះ ត្រូវបានអន្តរគណៈកម្មការជំនាញនៃរដ្ឋសភា សម្រេចឯកភាពជាមួយតំណាងរាជរដ្ឋាភិបាលហើយនឹងធ្វើសេចក្តីរាយការណ៍ជូន **សម្តេចប្រធានរដ្ឋសភា** និងគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ដើម្បីគោរពសុំដាក់បញ្ចូលក្នុងរបៀបវារៈសម័យប្រជុំពេញអង្គ នាពេលខាងមុខ៕

ឯកឧត្តម នឹម ច័ន្ទតារា ទទួលជួបពិភាក្សាការងារ ជាមួយអនុប្រធានបេសកកម្មស្ថានទូតចក្រភពអង់គ្លេស

ឯកឧត្តម **នឹម ច័ន្ទតារា** អនុប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន (គ៥) នៃរដ្ឋសភា នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២៦ បានអនុញ្ញាតជូន ឯកឧត្តម **ចូ រ៉ូលីង** (Joe Rolling) អនុប្រធានបេសកកម្មស្ថានទូតចក្រភពអង់គ្លេស ប្រចាំសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ និងសហការីចូលជួបសំណេះសំណាល និងពិភាក្សាការងារ នៅវិមានរដ្ឋសភា។

ឯកឧត្តម **នឹម ច័ន្ទតារា** ក្នុងនាម ***សម្តេចប្រធានរដ្ឋសភា*** បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះដំណើរទស្សនកិច្ចរបស់ ឯកឧត្តមអនុប្រធានបេសកកម្មស្ថានទូតចក្រភពអង់គ្លេសមកកាន់កម្ពុជា ក្នុងការរឹតចំណងកិច្ចសហប្រតិបត្តិការរវាងរដ្ឋសភានៃប្រទេសទាំងពីរ ឲ្យកាន់តែរឹងមាំទ្វេឡើងថែមទៀត។

ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អ និងយូរលង់រវាងប្រជាជាតិទាំងពីរ ត្រូវបានថ្នាក់ដឹកនាំបន្តសហការគ្នាបានយ៉ាងល្អប្រសើរ និងនាំមកនូវឧត្តមប្រយោជន៍ដល់ប្រទេសទាំងពីរ។ នៅក្នុងក្របខ័ណ្ឌនីតិប្បញ្ញត្តិ កិច្ចសហប្រតិបត្តិការបានស្តែងឡើង តាមរយៈការផ្លាស់ប្តូរទស្សនកិច្ចគ្នាទៅវិញទៅមកក្នុងកម្រិតគណៈកម្មការជំនាញ នៃប្រទេសទាំងពីរ និងការគាំទ្រគ្នាទៅវិញទៅមក ក្នុងវេទិកាអន្តរសភានានា នៅក្នុងតំបន់ និងសកលលោក។

ឯកឧត្តម **ចូ រ៉ូលីង** បានមានប្រសាសន៍ថា ជំនួបពិភាក្សានាពេលនេះ ធ្វើឡើងដើម្បីពង្រឹងពង្រីកទំនាក់ទំនងមិត្តភាពនិងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរឱ្យកាន់តែមានភាពរឹងមាំ រួមទាំងវិស័យសេដ្ឋកិច្ចផងដែរ។ ឯកឧត្តម បានសង្កេតឃើញពីភាពរួសរាយរាក់ទាក់របស់បងប្អូនពលរដ្ឋខ្មែរ និងភាពរីកចម្រើនលូតលាស់ លើគ្រប់វិស័យរបស់កម្ពុជា ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ។

ឯកឧត្តម **នឹម ច័ន្ទតារា** បានវាយតម្លៃខ្ពស់ចំពោះប្រសាសន៍លើកឡើងរបស់ ឯកឧត្តម ដែលបានឆ្លុះបញ្ចាំងអំពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងប្រទេសទាំងពីរ។ ឯកឧត្តមបញ្ជាក់ថា រដ្ឋសភាកម្ពុជាបាននិងកំពុងធ្វើការងារការទូតសភាយ៉ាងសកម្ម និងបានបង្កើតក្រុមមិត្ត ភាពរដ្ឋសភាជាមួយសភាប្រទេសជាមិត្ត នៅលើសកលលោកប្រមាណជាង ១៧០ប្រទេស មានទាំងសភាចក្រភពអង់គ្លេសផងដែរ៕

សម្ដេចក្រឡាហោម ស ខេង អញ្ជើញប្រគល់គ្រឿងឧបភោគបរិភោគ ជូនបញ្ជាការដ្ឋានយោធភូមិភាគទី៤ និងទី៥

សម្ដេចក្រឡាហោម **ស ខេង** ឧត្ដមប្រឹក្សផ្ទាល់ព្រះមហាក្សត្រ និងជាតំណាងរាស្ដ្រមណ្ឌលខេត្តបាត់ដំបង បានអញ្ជើញប្រគល់គ្រឿងឧបភោគបរិភោគជូនបញ្ជាការដ្ឋានយោធភូមិភាគទី៤ និងទី៥ នៅសាលាខេត្តបាត់ដំបង នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៦ និងអញ្ជើញអមដំណើរដោយ ឯកឧត្ដម **ឈាង ខុន** ឯកឧត្ដម **ច័ន្ទ សុផល** ឯកឧត្ដម **ឡោក ឃ្នីរ** លោកជំទាវ **លី គឹមលៀង** និងឯកឧត្ដម **ឆ្នួ ពុយ**។

ឯកឧត្ដម **សុខ លូ** អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង បានរាយការណ៍ពីការវិវត្តថ្មីៗ នៃស្ថានការណ៍ក្នុងខេត្តបាត់ដំបងជូន សម្ដេចក្រឡាហោម **ស ខេង** និងគណៈប្រតិភូ។

ឯកឧត្ដមអភិបាលខេត្ត បានថ្លែងអំណរគុណ **សម្ដេច និងលោកជំទាវ** ដែលតែងគិតគូរពីសុខទុក្ខរបស់វីរៈកងទ័ពជួរមុខ និងបានអញ្ជើញចុះសាកសួរសុខទុក្ខដល់បងប្អូនពលរដ្ឋភៀសសឹក ដែលរងគ្រោះពីការឈ្លានពានរបស់យោធាថៃ។

នៅក្នុងឱកាសនោះដែរ **សម្ដេចក្រឡាហោម** បានមានប្រសាសន៍ពាំនាំការផ្ដាំសាកសួរសុខទុក្ខពី សម្ដេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងសម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី ជូនដល់វីរៈកងទ័ពជួរមុខនៃយោធភូមិភាគទី៤ និងទី៥ ខេត្តបាត់ដំបង។

សម្ដេចក្រឡាហោម បានថ្លែងកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ ឯកឧត្ដមអភិបាលខេត្ត ឯកឧត្ដមប្រធានក្រុមប្រឹក្សាខេត្ត និងសហការីដែលបានលះបង់កម្លាំងកាយចិត្ត ខិតខំសហការជាមួយវីរៈកងទ័ពជួរមុខ និងបានរកទីទួលសុវត្ថិភាពព្រមទាំងផ្គត់ផ្គង់គ្រឿងឧបភោគបរិភោគគ្រប់គ្រាន់ជូនប្រជាពលរដ្ឋភៀសសឹក ដែលរងគ្រោះដោយសារសង្គ្រាមឈ្លានពាននេះ។ **សម្ដេច**បានថ្លែងនូវការដឹងគុណ និងអរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះវីរៈកងទ័ព និងមេបញ្ជាការគ្រប់ភូមិភាគ នៃខេត្តបាត់ដំបង ក៏ដូចជាគ្រប់ភូមិភាគទាំងអស់ជាប់ព្រំដែនខ្មែរ-ថៃ ដែលបានលះបង់កម្លាំងកាយចិត្តអាយុជីវិត ការពារបូរណភាពទឹកដី។

ក្នុងនាមតំណាងរាស្ដ្រ **សម្ដេច** បានថ្លែងនូវការអរគុណដ៏ជ្រាលជ្រៅ ចំពោះសប្បុរសជនទាំងអស់ដែលបានជួយបត្ថម្ភដល់រដ្ឋបាលខេត្តបាត់ដំបងរហូតមក តាមរយៈសម្ដេចផ្ទាល់ ក្រុមការងារក្រឡាហោមមនុស្សធម៌ និងសប្បុរសជននានា៕

គណៈប្រតិភូសភាកម្ពុជា ចូលរួមពិធីបើកមហាសន្និបាតលើកទី១៦ នៃសភាតំបន់អាស៊ី (APA-16) ស្តីពីសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព

គណៈប្រតិភូសភាកម្ពុជាដឹកនាំដោយ ឯកឧត្តម **ឌី ច័ន្ទផល** ប្រធានគណៈកម្មការទី១ ព្រឹទ្ធសភា និងឯកឧត្តម **អន្ត ខត្យខឡ្យនា** ប្រធានគណៈកម្មការទី៦ នៃរដ្ឋសភា ឯកឧត្តម **យស ផានីត្តា** ប្រធានគណៈកម្មការទី២ ព្រឹទ្ធសភា និងឯកឧត្តម **ស្មាន ម៉ាណាន** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំព្រះរាជាណាចក្របារ៉ែន និងមន្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា-រដ្ឋសភា នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៦ បានអញ្ជើញចូលរួមក្នុងពិធីបើកមហាសន្និបាតលើកទី១៦ (APA-16) នៃសភាតំបន់អាស៊ីស្តីពីសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព និងកិច្ចពិភាក្សាទូទៅក្នុងកិច្ចប្រជុំពេញអង្គ និងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍របស់ APA នៅទីក្រុងម៉ាណាម៉ា ប្រទេសបារ៉ែន។

ពិធីបើកមហាសន្និបាតប្រព្រឹត្តទៅដោយមានការអញ្ជើញជាអធិបតីពី **ឯកឧត្តម** (**Ahmed bin Salman Al-Musallam**) ប្រធានក្រុមប្រឹក្សាអ្នកតំណាងរាស្ត្រ នៃព្រះរាជាណាចក្របារ៉ែន និង ជាប្រធានសភាតំបន់អាស៊ី APA ដែលមានគណៈប្រតិភូប្រទេសជាសមាជិកចំនួន ១៩ និងអង្គការសង្កេតការណ៍ចំនួន៨ ព្រមទាំងអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ APA ផងដែរ។

ថ្លែងក្នុងឱកាសនៃកិច្ចពិភាក្សាទូទៅ ប្រធានគណៈប្រតិភូតំណាងសភាកម្ពុជា បានឡើងធ្វើសេចក្តីថ្លែងការណ៍ លើមូលបទរួមនៃមហាសន្និបាត លើកទី១៦ ស្តីពី "តួនាទី របស់សភាអាស៊ីក្នុងការពង្រឹងកិច្ចសន្ទនាអន្តរវប្បធម៌និងអន្តរអរិយធម៌នៅអាស៊ី៖ កាលានុវត្តភាព ភាពប្រឈម និងផ្លូវពេលអនាគត" ដោយបានសង្កត់ធ្ងន់លើភាពចម្រុះខាងអរិយធម៌ដ៏សម្បូរបែបរបស់អាស៊ី ដែលជាមូលដ្ឋានសម្រាប់ការសន្ទនា ដោយបានបញ្ជាក់ពីឱកាសក្នុងការលើកកម្ពស់ភាពអត់ឱន ការចូលរួមរបស់យុវជន និងគោលនយោបាយរួមបញ្ចូល។ ការទទួលស្គាល់បញ្ហាប្រឈមដូចជា ភាពជ្រុលនិយម ព័ត៌មានក្លែងក្លាយ និងការបែងចែកសង្គម ព្រមទាំងបានអំពាវនាវឱ្យសភាអាស៊ី ពង្រឹងក្របខ័ណ្ឌច្បាប់កិច្ចសហប្រតិបត្តិការក្នុងតំបន់ និងការអប់រំ ដើម្បីកសាងអាស៊ីមួយដែលមានសន្តិភាព សុខដុមរមនា និងវិបុលភាព។

ចំពោះកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពីសេដ្ឋកិច្ចនិងការអភិវឌ្ឍប្រកបដោយចីរភាព។ អង្គប្រជុំ បានសម្រេចអនុម័តលើសេចក្តីសម្រេច

ចំនួនបី ដើម្បីដាក់ជូនមហាសន្និបាត រួមមាន៖
(១) កិច្ចការហិរញ្ញវត្ថុ
(២) អនាម័យ និងទឹកនៅក្នុងតំបន់អាស៊ីជារួម និង(៣) គោលការណ៍សេដ្ឋកិច្ចហាឡាល។

នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **អេង វណ្ណ វឌ្ឍានា** ប្រធានគណៈកម្មការទី៦ នៃរដ្ឋសភានិងជាប្រធានក្រុមសភាជាតិកម្ពុជានៃសភាតំបន់អាស៊ី ឯកឧត្តម **យស ផានីត្តា** ប្រធានគណៈកម្មការទី២ នៃព្រឹទ្ធសភា និងឯកឧត្តម **ងី ច័ន្ទ្រផល** ប្រធានគណៈកម្មការទី១ នៃព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំពាក់ព័ន្ធរបស់សភាតំបន់អាស៊ី ស្តីពីកិច្ចការនយោបាយ កិច្ចការសង្គមនិងវប្បធម៌ កិច្ចការថវិកា និងផែនការ និងពិធីបិទមហាសន្និបាតលើកទី១៦នៃសភាតំបន់អាស៊ី នៅទីក្រុងម៉ាណាម៉ា ព្រះរាជាណាចក្របារ៉ែន។

មហាសន្និបាតលើកទី១៦នៃសភាតំបន់អាស៊ីបានអនុម័តសេចក្តីសម្រេចចំនួន២៧ដែលបានរៀបចំដោយគណៈកម្មាធិការអចិន្ត្រៃយ៍ទាំង៤ និង សេចក្តីប្រកាសទីក្រុងម៉ាណាម៉ា។

មហាសន្និបាតបានសម្រេចលើប្រធានដឹកនាំ និងទទួលធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំគណៈកម្មា-

ធិការអចិន្ត្រៃយ៍ទាំង៤ របស់ APA សម្រាប់ឆ្នាំ ២០២៦ គឺប្រទេសអ៊ីរ៉ង់ នឹងត្រូវទទួលធ្វើជាប្រធានកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍កិច្ចការសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព។ ប្រទេសតាហ្ស៊ីគីស្ថាន ជាប្រធាននៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍កិច្ចការសង្គមនិងវប្បធម៌ ប្រទេសហ្សកដានី ជាប្រធានកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍កិច្ចការនយោបាយ និងប្រទេសកាតា ជាប្រធានកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍កិច្ចការផែនការ និងថវិកា។

សូមជម្រាបថា ក្នុងអំឡុងពេលមហាសន្និបាតលើកទី១៦នេះ គណៈប្រតិភូសភាកម្ពុជា ត្រូវបានជ្រើសតាំង ជាអ្នករាយការណ៍ផងដែរ៕

ឯកឧត្តម ទី សុគន្ធ ដឹកនាំគណៈប្រតិភូចូលរួមប្រជុំគណៈកម្មាធិការសិក្សា ស្តីពីការកែទម្រង់ AIPACODD នៅប្រទេសឥណ្ឌូណេស៊ី

ឯកឧត្តម **ទី សុគន្ធ** លេខាធិការគណៈកម្មការទី៥ នៃរដ្ឋសភា នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៦ បានដឹកនាំគណៈប្រតិភូចូលរួមកិច្ចប្រជុំលើកទី១ នៃគណៈកម្មាធិការសិក្សា ស្តីពីការកែទម្រង់ក្រុមប្រឹក្សាពិគ្រោះយោបល់អាយប៉ា ស្តីពីគ្រោះថ្នាក់គ្រឿងញៀន (ASEAN Inter-Parliamentary Assembly Advisory Council on Dangerous Drugs (AIPACODD) ចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៦ នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូណេស៊ី ។

កិច្ចប្រជុំនេះ បានពិភាក្សា និងសិក្សាលើការកែទម្រង់ AIPACODD ឱ្យទៅជាយន្តការថ្មីដែលមានវិសាលភាពទូលំទូលាយជាងមុនក្នុងការឆ្លើយតបនឹងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់រូបភាព រួមមានបទល្មើសបច្ចេកវិទ្យា ការជួញដូរមនុស្ស និងការជួញដូរគ្រឿងញៀន ឱ្យស្របតាមចក្ខុវិស័យអាស៊ាន ឆ្នាំ២០៤៥។

ឯកឧត្តម **ទី សុគន្ធ** បានចូលរួមចែករំលែកមតិយោបល់នៅគ្រប់សម័យប្រជុំ និងផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចជា ការពង្រឹងការឆ្លើយតបតាមផ្លូវច្បាប់ចំពោះការគំរាមកំហែងដែលកំពុងកើតមានក៏ដូចជាការបង្កើតយន្តការតំបន់ដើម្បីដោះស្រាយបទល្មើសឆ្លងដែន។

ឯកឧត្តមបានបញ្ជាក់បន្ថែមថា “ការឈ្លានពានដោយប្រដាប់អាវុធ និងអំពើហិង្សាឆ្លងដែនរបស់កងទ័ពថៃមកលើប្រទេស និងប្រជាពលរដ្ឋខ្មែរ គឺជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់អន្តរជាតិ និងជាការគំរាមកំហែងឆ្លងដែន ដែលប៉ះពាល់ដល់ស្ថិរភាពតំបន់ និងមជ្ឈភាពអាស៊ាន”។

គណៈប្រតិភូរដ្ឋសភាកម្ពុជា បានអំពាវនាវឱ្យមានការគោរពនិងអនុវត្តតាមច្បាប់អន្តរជាតិក្នុងការដោះស្រាយបញ្ហាឧក្រិដ្ឋកម្មឆ្លងដែនទាំងអស់ តាមរយៈកិច្ចសហប្រតិបត្តិការតំបន់និងអន្តរជាតិហើយ ជៀសវាងការប្រើប្រាស់កម្លាំងយោធាឈ្លានពាន ដែលប៉ះពាល់ដល់សន្តិសុខ អធិបតេយ្យជាតិ និងបូរណភាពទឹកដីរបស់រដ្ឋជាសមាជិក ដូចមានចែងក្នុងធម្មនុញ្ញសហប្រជាជាតិ សន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិនានា៕

មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភា រួមសហការវេចខ្ចប់ លើកដាក់អង្ករ និងសម្ភារនានា បញ្ជូនទៅឧបត្ថម្ភវីរយុទ្ធជន និងពលរដ្ឋភៀសសឹក

នៅថ្ងៃអាទិត្យ ទី៤ ខែមករា ឆ្នាំ២០២៦ ទោះបីជាពេលវេលាឈប់សម្រាកយ៉ាណាក្តី ក៏ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា បានចូលរួមយ៉ាងសកម្ម ស្ម័គ្រចិត្តវេចខ្ចប់ លើកដាក់អង្ករ សម្ភារប្រើប្រាស់ ព្រមទាំងគ្រឿងឧបភោគបរិភោគ ដែលជាអំណោយរបស់ សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បញ្ជូនទៅឧបត្ថម្ភគាំទ្រដល់វីរយុទ្ធជន នៅសមរភូមិមុខ និងពលរដ្ឋភៀសសឹក។

ចាប់តាំងពីខែកក្កដាឆ្នាំ២០២៥មក សប្បុរសជន និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា សមាជិក សមាជិការដ្ឋសភា ទីប្រឹក្សា ជំនួយការ **សម្តេចប្រធានរដ្ឋសភា** បានចូលរួមបរិច្ចាគថវិកា សម្ភារនានា ក៏ដូចជាកម្លាំងកាយចិត្ត តាមរយៈ **សម្តេច** ឆ្លើយតបទៅនឹងការអំពាវនាវរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី និងសម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ក្នុងស្មារតីសមរភូមិក្រោយនៅជាប់ជានិច្ច និងគាំទ្រពេញទំហឹងចំពោះសមរភូមិមុខ ក្នុងគ្រាដ៏លំបាក ដែលប្រទេសជាតិទទួលរងការឈ្លានពានលើបូរណភាពទឹកដី ពីប្រទេសជិតខាង។

មហាសាមគ្គីគ្រួសារខ្មែរបានរួមគ្នាជាធ្លុងមួយ និងផុសឡើងយ៉ាងរឹងមាំ ខ្លាំងក្លាបំផុត ឈរយ៉ាងស្វាហាប់ពីក្រោយរាជរដ្ឋាភិបាល និងវីរយុទ្ធជនយើង។ មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភា បានអះអាងថា សកម្មភាពមនុស្សធម៌នាពេលនេះ ជាការឆ្លើយតបចំពោះគុណបំណាច់ដ៏ធំធេងរបស់វីរយុទ្ធជន ក្នុងកិច្ចការពារបូរណភាពទឹកដីយ៉ាងអង់អាចក្លាហាននៅសមរភូមិជួរមុខ។

សម្តេចរដ្ឋសភាធិបតី **ឃួន សុដារី** ធ្លាប់បានលើកឡើងថា សកម្មភាពមនុស្សធម៌មហាគ្រួសារខ្មែរគឺជាការឆ្លុះបញ្ចាំងអំពីការរួមចំណែករបស់ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក និងលោកស្រី ក្នុងស្មារតីសាមគ្គីភាព ស្នេហាជាតិ «ខ្មែរជួយខ្មែរ» នៅគ្រប់កាលៈទេសៈជាមួយរាជរដ្ឋាភិបាល។

សម្តេចប្រធានរដ្ឋសភាបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូន ថ្នាក់ដឹកនាំ សមាជិក សមាជិការដ្ឋសភា និងមន្ត្រីរដ្ឋសភា សប្បុរសជនទាំងអស់ ដែលបានចំណាយធនធាន កម្លាំងកាយចិត្ត និងពេលវេលាចូលរួមយ៉ាងសស្រាក់សស្រាំ ជាមួយមហាសាមគ្គីគ្រួសារខ្មែរនាឱកាសនេះ៕

ឯកឧត្តមបណ្ឌិត កែវ ពិសិដ្ឋ ដឹកនាំកិច្ចប្រជុំសម្រេចលើគម្រោងបណ្តុះបណ្តាល មន្ត្រីអគ្គនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ពិធីការ និងព័ត៌មាន សម្រាប់ឆ្នាំ២០២៦

ឯកឧត្តមបណ្ឌិត **កែវ ពិសិដ្ឋ** អគ្គលេខាធិការរងប្រចាំការនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា និងជានាយកខុទ្ទកាល័យសម្តេចប្រធានរដ្ឋសភា នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០២៦ បានអញ្ជើញដឹកនាំកិច្ចប្រជុំក្រុមការងាររៀបចំវគ្គបណ្តុះបណ្តាល នៃអគ្គនាយកដ្ឋានទំនាក់ទំនងអន្តរជាតិពិធីការនិងព័ត៌មាន (អ.ទ.ព.ព) ដើម្បីពិនិត្យ និងសម្រេចលើគម្រោងបណ្តុះបណ្តាលមន្ត្រីសម្រាប់ ឆ្នាំ២០២៦ នៅវិមានរដ្ឋសភា។

វគ្គបណ្តុះបណ្តាល នឹងសិក្សាលើមុខជំនាញ ប្រវត្តិនយោបាយការបរទេសកម្ពុជា និងសេដ្ឋកិច្ចកម្ពុជា ការសរសេរលិខិតឆ្លើយឆ្លងជាភាសាអង់គ្លេស ជំនាញសរសេរ និងចាប់មុំព័ត៌មាន ជំនាញថែទាំ និងទុកដាក់ឯកសារ ជំនាញបដិសណ្ឋារកិច្ចផ្លូវការ និងពិធីការបែបសាសនា ជំនាញភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ចពិភពលោក ទំនាក់ទំនងការទូត ការសរសេរលិខិតរដ្ឋបាល ជំនាញប្រើប្រាស់កុំព្យូទ័រ Microsoft Word និង PowerPoint ជំនាញថតរូបភាព-ថតវីដេអូនិងកាត់តវីដេអូជំនាញទស្សនាទានសំខាន់ៗក្នុងការយល់ដឹងពីវិស័យ ការ ទូត និងទំនាក់ទំនងអន្តរជាតិ ជំនាញ Cyber Security សម្រាប់ការគ្រប់គ្រងគេហទំព័រ និងបណ្តាញសង្គម និងការទូតសភាបែបពហុភាគី AIPA & IPU។ ការបណ្តុះបណ្តាលនេះ ផ្តោតលើមន្ត្រីមកពីនាយកដ្ឋានទាំងបី នៃអគ្គនាយកដ្ឋាន (ទ.ព.ព) រួមមាន៖

(១) នាយកដ្ឋានទំនាក់ទំនង៖ វគ្គនេះនឹងពង្រឹងជំនាញឯកទេសបន្ថែមទៀត បង្កើនការយល់ដឹងស៊ីជម្រៅក្នុងទំនាក់ទំនងអន្តរជាតិ ភូមិសាស្ត្រនយោបាយ គោលនយោបាយការបរទេស និងការទូតសភា។ ពង្រឹងការផ្តល់សេវាក្នុងការគាំទ្រប្រកបដោយវិជ្ជាជីវៈ និងទាន់ពេលវេលាជូនដល់សមាជិកសមាជិការដ្ឋសភា និងថ្នាក់ដឹកនាំ។ ជំរុញការបង្កើតថ្មី និងសម្របខ្លួននឹងការវិវត្តនៃតម្រូវការស្ថាប័ន។

(២) នាយកដ្ឋានពិធីការ៖ ការបណ្តុះបណ្តាលនឹងផ្តល់បន្ថែមដល់មន្ត្រី នូវការយល់ដឹងអំពីគោលការណ៍គ្រឹះនៃពិធីបដិសណ្ឋារកិច្ច ទំនាក់ទំនងការទូត និងពិធីការផ្លូវការ ជាពិសេសក្នុងបរិបទថ្មី។ ការរៀបចំសម្របសម្រួល និងគ្រប់គ្រងព្រឹត្តិការណ៍ផ្លូវការ កិច្ចប្រជុំ ពិធីទទួលភ្ញៀវជាតិ-អន្តរជាតិ និងដំណើរទស្សនកិច្ចនានា ប្រកបដោយប្រសិទ្ធភាព និងភាពថ្លៃថ្នូរ។ លើកកម្ពស់តរិយាបថ និងក្រមសីលធម៌

វិជ្ជាជីវៈខ្ពស់ ស្របតាមបទដ្ឋាននៃការទូត និងវប្បធម៌ខ្មែរក្នុងទំនាក់ទំនងជាមួយថ្នាក់ដឹកនាំ មន្ត្រីជាន់ខ្ពស់ គណៈប្រតិភូបរទេសនិងសាធារណជន និងឱ្យមន្ត្រីយល់ដឹងពីរបៀបនៃការរៀបចំពិធីសាសនា រួមមាន ពិធីក្រុងពាលី ពិធីសែនព្រេន ពិធីសូត្រមន្ត ពិធីបុណ្យសព ពិធីគោរពវិញ្ញាណក្ខន្ធ។ល។

(៣) នាយកដ្ឋានព័ត៌មាន៖ វគ្គទាំងនេះនឹងជួយពង្រឹងសមត្ថភាពវិជ្ជាជីវៈ លើជំនាញសរសេរបោះពុម្ពព័ត៌មាន បច្ចេកទេសវិភាគ គំនិតច្នៃប្រឌិត ប្រភពទិន្នន័យត្រឹមត្រូវ អត្ថបទមានខ្លឹមសារល្អ រចនាបថច្បាស់លាស់សមស្របនឹងតួនាទីរដ្ឋសភាឆ្លើយតបនឹងផលប្រយោជន៍សាធារណៈ។ បង្កើនការផលិត និងរក្សាទុក ចែករំលែកចំណេះលើការថត រូបភាព ផលិតវីដេអូ ថែទាំរក្សាទុកឯកសារដែលបានផលិតរួច ដើម្បីងាយស្វែងរកសម្រាប់ការប្រើប្រាស់បន្ត និងអភិវឌ្ឍប្រកបដោយគុណភាព និង រហ័ស។ ពង្រីកការយល់ដឹង និងការពារសន្តិសុខព័ត៌មាន បង្កើនការយល់ដឹងអំពីហានិភ័យសន្តិសុខសាយប័រ និងអនុវត្តវិធានការការពារគេហទំព័រ និងបណ្តាញសង្គមផ្លូវការរបស់រដ្ឋសភាឱ្យមានសុវត្ថិភាព និងទំនុកចិត្តខ្ពស់៕

ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានរដ្ឋសភា ស្នើសាកលវិទ្យាល័យថុងជី ប្រទេសចិន ជំរុញការលើកកម្ពស់កិច្ចការស្រាវជ្រាវជាមួយរដ្ឋសភាកម្ពុជា

ឯកឧត្តមបណ្ឌិត **ឈាង វណ្ណារិទ្ធ** អគ្គលេខាធិការរង និងជាប្រធានក្រុមទីប្រឹក្សារដ្ឋសភា នៅរសៀលថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៦ បានទទួលជួបពិភាក្សាការងារជាមួយ លោកព្រឹទ្ធបុរស **ម៉េង ហុងហួរ** (Meng Honghua) ព្រឹទ្ធបុរសមហាវិទ្យាល័យវិទ្យាសាស្ត្រនយោបាយ និងទំនាក់ទំនងអន្តរជាតិ និងជាប្រធានវិទ្យាស្ថានស្រាវជ្រាវយុទ្ធសាស្ត្រចិន នៃសាកលវិទ្យាល័យថុងជី នៅវិមានរដ្ឋសភា។

កិច្ចពិភាក្សានេះ បានផ្តោតសំខាន់លើចំណងមិត្តភាពជាប្រពៃណីរវាងប្រជាជន និងប្រជាជនកម្ពុជា-ចិននិងការលើកកម្ពស់កិច្ចការស្រាវជ្រាវរវាងរដ្ឋសភាកម្ពុជាជាមួយគ្រឹះស្ថានឧត្តមសិក្សានៃប្រទេសចិន។ ឯកឧត្តមបណ្ឌិត **ឈាង វណ្ណារិទ្ធ** បានឆ្លុះបញ្ចាំងពីទំនាក់ទំនងដ៏ជិតស្និទ្ធរវាងប្រទេសទាំងពីរ ជាពិសេសទំនាក់ទំនងរវាងប្រជាជន និងប្រជាជន និងកម្មវិធីផ្លាស់ប្តូរវិស័យសិក្សាស្រាវជ្រាវ និងបង្ហាញក្តីសង្ឃឹមថា ភាគីចិននឹងបន្តលើកកម្ពស់ និងជំរុញបន្ថែមនូវកម្មវិធីផ្លាស់ប្តូរការសិក្សាស្រាវជ្រាវ និងការផ្លាស់ប្តូររវាងប្រជាជន និងប្រជាជន ពីព្រោះទំនាក់ទំនងរវាងប្រទេសទាំងពីរ ត្រូវបានពង្រឹង ដោយយកប្រជាជនជាស្នូល។ លើសពីនេះ ឯកឧត្តមបណ្ឌិតក៏បានលើកឡើងពីសារៈសំខាន់នៃការពង្រឹងយន្តការពិភាក្សាជាយុទ្ធសាស្ត្រ

រវាងប្រទេសទាំងពីរ ដើម្បីធ្វើដំណើររួមគ្នាទៅមុខក្នុងអនាគត បញ្ចៀសហានិភ័យផ្សេងៗ និងបង្កើនភាពធន់របស់កម្ពុជា។

ឯកឧត្តមបណ្ឌិត បានបញ្ជាក់ថា «កម្ពុជាមិនចូលរួមក្នុងសម្ព័ន្ធណាមួយទេ ប៉ុន្តែកម្ពុជាផ្តល់អាទិភាពជាចម្បង ដល់ផលប្រយោជន៍ជាតិ» កម្ពុជាតែងយកប្រជាជនជាស្នូលក្នុងអភិបាលកិច្ច និងគោលនយោបាយអន្តរជាតិ ហើយកិច្ចសហប្រតិបត្តិការត្រូវបានកំណត់ដោយផលប្រយោជន៍ស្នូលរបស់ជាតិ និងបរិបទជាក់លាក់នៅក្នុងតំបន់ និងអន្តរជាតិ។

លោកព្រឹទ្ធបុរស **ម៉េង ហុងហួរ** បានលើកឡើងថា ការកើនឡើងវិញនៃការប្រកួតប្រជែងរវាងអំណាចធំៗ បានបង្កើនតម្រូវការសម្រាប់ការចូលរួមប្រកបដោយទំនួលខុសត្រូវក្នុងតំបន់។

ក្នុងបរិបទនេះភាគីចិនបានគូសបញ្ជាក់ពីតួនាទីរបស់ប្រទេសចិនក្នុងការគាំទ្រស្ថិរភាព និងការអភិវឌ្ឍនៅតំបន់អាស៊ី។ ជាមួយគ្នានោះ ភាគីចិនបានវាយតម្លៃខ្ពស់លើទំនាក់ទំនង «ដែកថែប» រវាងកម្ពុជា និងចិន ហើយបានបន្តជំរុញឲ្យទំនាក់ទំនងទ្វេភាគីនេះត្រូវបានលើកកម្ពស់ទៅកម្រិតខ្ពស់ជាងមុន។ ភាគីចិនក៏បានបញ្ជាក់ថា កម្ពុជាត្រូវបានចាត់ទុកជាមិត្តដ៏សំខាន់មួយរបស់ប្រទេសចិន នៅក្នុងតំបន់៕

អគ្គលេខាធិការដ្ឋានរដ្ឋសភា រៀបចំវគ្គបណ្តុះបណ្តាលស្តីពី «ជំនាញតាក់តែងសង្ខេបគោលនយោបាយ»

ឯកឧត្តម **ឡេង ប៉េងឡុង** អគ្គលេខាធិការរដ្ឋសភា នាព្រឹកថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៦ បានអញ្ជើញជាអធិបតី ក្នុងពិធីបើកវគ្គបណ្តុះបណ្តាលស្តីពី «ជំនាញក្នុងការតាក់តែងសង្ខេបគោលនយោបាយ» ជូនដល់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានរដ្ឋសភាចំនួន ៦០រូប នៅវិមានរដ្ឋសភា។

ថ្លែងក្នុងពិធីបើកវគ្គបណ្តុះបណ្តាល ឯកឧត្តម **ឡេង ប៉េងឡុង** បានមានប្រសាសន៍ថា អគ្គលេខាធិការដ្ឋានរដ្ឋសភា មានភារកិច្ចស្នូលក្នុងការផ្តល់សេវាផ្សេងៗ និងសម្របសម្រួលការងារជូនតំណាងរាស្ត្រឱ្យបានល្អប្រសើរ។ ដើម្បីសម្រេចបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការបំពេញការងារជូនរដ្ឋសភា មន្ត្រីរាជការទាំងអស់ ចាំបាច់ត្រូវទទួលបានការបណ្តុះបណ្តាលជាប្រចាំ ដើម្បីពង្រឹងសមត្ថភាព និងជំនាញឱ្យបានគ្រប់ជ្រុងជ្រោយលើគ្រប់វិស័យ។

ឯកឧត្តមអគ្គលេខាធិការ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តមបណ្ឌិត **ឈាង ចណ្ឌារិទ្ធ** ដែលបានផ្តួចផ្តើមក្នុងការរៀបចំវគ្គបណ្តុះបណ្តាលដ៏មានសារៈសំខាន់នេះ ព្រមទាំងអរគុណ ដល់គ្រូឧទ្ទេសទាំងអស់ ដែលបានខិតខំចែករំលែកចំណេះដឹង និងបទពិសោធន៍ដល់សិក្ខាកាមទាំងអស់។

ឯកឧត្តមបានផ្តាំផ្ញើដល់សិក្ខាកាម ត្រូវយកចិត្តទុកដាក់ក្រេបជញ្ជក់យកចំណេះដឹង ឱ្យបានហ្មត់ចត់ដើម្បីយកទៅអនុវត្ត និងពង្រឹងគុណភាពការងារផ្ទាល់ខ្លួន ក៏ដូចជាបម្រើដល់ឧត្តមប្រយោជន៍របស់សភាជាតិកម្ពុជា ឱ្យកាន់តែរីកចម្រើនឡើង៕

អគ្គលេខាធិការដ្ឋានរដ្ឋសភា រៀបចំប្រឡងជ្រើសរើសមន្ត្រីកិច្ចសន្យា លើជំនាញព័ត៌មានវិទ្យា និងសារព័ត៌មាន

ឯកឧត្តម **ឡេង ប៉េងឡុង** អគ្គលេខាធិការរដ្ឋសភា និងជាប្រធានគណៈកម្មការប្រឡងជ្រើសរើសមន្ត្រីកិច្ចសន្យា នាព្រឹកថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៦បានអញ្ជើញជាអធិបតីបើកវិញ្ញាសាប្រឡងជ្រើសរើសមន្ត្រីកិច្ចសន្យា ផ្នែកសារព័ត៌មាន ផ្នែកកាត់តវីដេអូ ផ្នែកបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ចំនួន៣៥នាក់ នៅវិមានរដ្ឋសភា។

វត្តមានអញ្ជើញចូលរួមកម្មវិធីបើកវិញ្ញាសាប្រឡង នាពេលនោះ រួមមាន ឯកឧត្តមបណ្ឌិត **កែវ ពិសិដ្ឋ** អគ្គលេខាធិការរងប្រចាំការរដ្ឋសភា និងជានាយកខុទ្ទកាល័យសម្ដេចប្រធានរដ្ឋសភា ឯកឧត្តម **ឃួន ដាវិត** អគ្គលេខាធិការរងរដ្ឋសភា និងឯកឧត្តម លោក លោកស្រី ជាសមាជិកគណៈកម្មការប្រឡងជ្រើសរើសមន្ត្រីកិច្ចសន្យាមួយចំនួនទៀតផងដែរ។

ការប្រឡងជ្រើសរើសមន្ត្រីកិច្ចសន្យានេះ មានបេក្ខជន បេក្ខនារី បានដាក់ពាក្យប្រឡងសរុបចំនួន ១០៩នាក់ ប្រុស ៩៣នាក់ និងស្រី ១៦នាក់ ប៉ុន្តែបេក្ខជនមកចូលរួមប្រឡងជាក់ស្តែង មានចំនួន ៧៧នាក់ និងប្រព្រឹត្តទៅរយៈពេល ១ថ្ងៃ លើវិញ្ញាសាសរសេរ និងវិញ្ញាសាអនុវត្ត។

សូមជម្រាបថា អគ្គលេខាធិការដ្ឋានរដ្ឋសភា បានបង្កើតគណៈកម្មការ និងអនុគណៈកម្មការមួយចំនួន សម្រាប់រៀបចំការប្រឡងជ្រើសរើសមន្ត្រីកិច្ចសន្យា ដើម្បីប្រាកដថា ការប្រឡប្រព្រឹត្តទៅដោយតម្លាភាព ត្រឹមត្រូវ និងយុត្តិធម៌ ក្នុងការជ្រើសមន្ត្រីដែលមានសមត្ថភាព និងវិជ្ជាជីវៈ មកបំពេញការងារជូនថ្នាក់ដឹកនាំ សមាជិក សមាជិការដ្ឋសភា ក៏ដូចជាអគ្គលេខាធិការដ្ឋានរដ្ឋសភា៕

អគ្គលេខាធិការដ្ឋានរដ្ឋសភា បើកសម្ពោធជាផ្លូវការ វគ្គបណ្តុះបណ្តាលឆ្នាំ២០២៦ ដើម្បីពង្រឹងសមត្ថភាពមន្ត្រីអគ្គនាយកដ្ឋាន ទំនាក់ទំនងអន្តរជាតិ ពិធីការ និងព័ត៌មាន

ឯកឧត្តម **ឡេង ប៉េងឡុង** អគ្គលេខាធិការរដ្ឋសភា បានអញ្ជើញជាអធិបតីពិធីបើកសម្ពោធជាផ្លូវការវគ្គបណ្តុះប្រចាំឆ្នាំ២០២៦ របស់អគ្គនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ពិធីការ និងព័ត៌មាន (អ.ទ.ព.ព.) និងបើកវគ្គបណ្តុះបណ្តាលស្តីពី «ការតាក់តែងលិខិតក្នុងការងារទំនាក់ទំនងអន្តរជាតិ ជាភាសាអង់គ្លេស» នៅវិមានរដ្ឋសភា ព្រឹកថ្ងៃទី២០ ខែមករា ឆ្នាំ២០២៦។

ក្នុងពិធីបើកវគ្គបណ្តុះបណ្តាលនេះ មានការអញ្ជើញចូលរួមពី ឯកឧត្តមបណ្ឌិត **កែវ ពិសិដ្ឋ** អគ្គលេខាធិការរងប្រចាំការ និងជានាយកខុទ្ទកាល័យសម្តេចប្រធានរដ្ឋសភា ឯកឧត្តមបណ្ឌិត **ឈាង វណ្ណារិទ្ធ** អគ្គលេខាធិការរង និងជាប្រធានក្រុមទីប្រឹក្សារដ្ឋសភា ឯកឧត្តម **ព្រហ្ម ថិរៈ** អគ្គនាយក ទ.ព.ព ព្រមទាំងអគ្គនាយករង ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន និងមន្ត្រីចូលរួមចំនួន ១៣៣នាក់។

ថ្លែងក្នុងពិធីបើកវគ្គបណ្តុះបណ្តាលនេះ ឯកឧត្តម **ឡេង ប៉េងឡុង** បានមានប្រសាសន៍លើកឡើងថា អគ្គលេខាធិការដ្ឋានរដ្ឋសភាមានភារកិច្ចស្នូលក្នុងការផ្តល់សេវា និងសម្របសម្រួលការងារជូនតំណាងរាស្ត្រឱ្យបានល្អប្រសើរ ដើម្បីសម្រេចបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការបម្រើការងារជូនសភាជាតិ។

ឯកឧត្តមអគ្គលេខាធិការ បានគូសបញ្ជាក់ថា «មន្ត្រីរាជការទាំងអស់ ចាំបាច់ត្រូវតែទទួលបានការបណ្តុះបណ្តាលជាប្រចាំ ដើម្បីពង្រឹងសមត្ថភាព និងជំនាញឱ្យបានគ្រប់ជ្រុងជ្រោយលើគ្រប់វិស័យ»។

ឯកឧត្តមបានជំរុញដល់សិក្ខាកាមទាំងអស់ត្រូវយកចិត្តទុកដាក់លើការសិក្សា និងយកទៅអនុវត្តដើម្បីពង្រឹងគុណភាពការងារផ្ទាល់ខ្លួន ក៏ដូចជារួមចំណែកក្នុងការបម្រើឧត្តមប្រយោជន៍របស់សភាជាតិកម្ពុជា។

ឯកឧត្តមបណ្ឌិត **កែវ ពិសិដ្ឋ** បានមានប្រសាសន៍ថា «វគ្គបណ្តុះបណ្តាលប្រចាំឆ្នាំ ២០២៦ នេះ ជាផ្លែផ្កានៃកិច្ចសហការរបស់អគ្គនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ពិធីការ និងព័ត៌មាន»។

ឯកឧត្តមបណ្ឌិត បានបន្ថែមថា ការបណ្តុះបណ្តាលនេះ ជាតម្រូវការចាំបាច់បំផុត ដើម្បីជានាថា មន្ត្រីនៃនាយកដ្ឋាននីមួយៗ នឹងទទួលបាននូវចំណេះដឹង ឆ្លើយតបចំគោលដៅការងារ ក៏ដូចជាការពង្រឹងសមត្ថភាពបន្ថែមទៀតផងដែរ។

បន្ទាប់ពីពិធីបើកជាផ្លូវការ វគ្គបណ្តុះបណ្តាលទី១ ប្រចាំឆ្នាំ២០២៦នេះ បានដំណើរការក្រោមប្រធានបទ «ការតាក់តែងលិខិត ក្នុងការងារទំនាក់ទំនងអន្តរជាតិ ជាភាសាអង់គ្លេស» ដើម្បីពង្រឹងសមត្ថភាពមន្ត្រី លើការសរសេរលិខិតឆ្លើយឆ្លងដោយការប្រើប្រាស់វាក្យសព្ទ និងបច្ចេកសព្ទភាសាអង់គ្លេសឱ្យមានភាពត្រឹមត្រូវ ច្បាស់លាស់ ស្របតាមក្របខ័ណ្ឌការងារទំនាក់ទំនងអន្តរជាតិ។

វគ្គបណ្តុះបណ្តាលនេះ ទទួលបានការឧទ្ទេសពីឯកឧត្តមបណ្ឌិត **ឈាង ចណ្ណារិទ្ធ** អគ្គលេខាធិការរង រដ្ឋសភា។

សូមជម្រាបជូនថា ក្នុងឆ្នាំ២០២៦ អគ្គនាយកដ្ឋាន ទ.ព.ព នឹងផ្តល់វគ្គបណ្តុះបណ្តាលចំនួន ១៤ មុខជំនាញ រួមមាន៖

១-ការតាក់តែងលិខិត ក្នុងការងារទំនាក់ទំនងអន្តរជាតិ ជាភាសាអង់គ្លេស

២-ជំនាញសរសេរ និងចាប់មុំព័ត៌មាន

៣-ប្រវត្តិនយោបាយការបរទេសកម្ពុជា និងសេដ្ឋកិច្ចកម្ពុជា

៤-ជំនាញថែទាំ និងទុកដាក់ឯកសារ

៥-បដិសណ្ឋារកិច្ចផ្លូវការ និងពិធីការបែបសាសនា

៦-ទំនាក់ទំនងការទូត

៧-ភូមិសាស្ត្រនយោបាយនិងសេដ្ឋកិច្ចពិភពលោក

៨-ការសរសេរលិខិតរដ្ឋបាល

៩-ជំនាញប្រើប្រាស់ Microsoft Word

១០-ជំនាញថតរូប ថតវីដេអូ និងកាត់តវីដេអូ

១១-ជំនាញប្រើប្រាស់ Power Point

១២-ទស្សនទានសំខាន់ៗ ក្នុងការយល់ដឹងពីវិស័យការទូត និងទំនាក់ទំនងអន្តរជាតិ

១៣-ជំនាញ Cyber Security សម្រាប់ការគ្រប់គ្រងគេហទំព័រ និងបណ្តាញសង្គម

១៤-ការទូតសភា បែបពហុភាគី AIPA និង IPU ៕